# និន្នាការនៃការបំពានតាមអនឡាញ ដែលយាយី ដល់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា

## របាយការណ៍ឃ្លាំមើលបណ្តាញទំនាក់ទំនងសង្គមប្រចាំត្រីមាស ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦

របាយការណ៍ប្រចាំត្រីមាសទីពីរ៖ ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦

កាលបរិច្ឆេទនៃការឃ្លាំមើល៖ ពីថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៦

កាលបរិច្ឆេទចេញរបាយការណ៍៖ ខែមិថុនា ឆ្នាំ២០២៦

## និយមន័យ

ផ្នែកនេះពន្យល់អំពីពាក្យគន្លឹះសំខាន់ៗដែលត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ។ ពាក្យមួយចំនួនក្នុងចំណោមពាក្យទាំងនេះ គឺជាពាក្យបច្ចេកទេស ហើយអាចនឹងមិនសូវមានភាពស៊ាំ (មិនសូវស្គាល់) ចំពោះអ្នកអានទាំងអស់នោះទេ។

**គណនីមិនពិតប្រាកដ (Inauthentic Account)៖** សំដៅលើគណនីហ្វេសប៊ុក (Facebook) ដែលមិនត្រូវបានបង្កើតឡើងសម្រាប់ការប្រើប្រាស់ជាលក្ខណៈបុគ្គលធម្មតានោះទេ។ នៅក្នុងរបាយការណ៍នេះ គណនីមួយត្រូវបានចាត់ទុកថាជាគណនីមិនពិតប្រាកដ ប្រសិនបើគណនីនោះទើបតែត្រូវបានបង្កើតឡើងថ្មីៗ ហើយបង្ហាញសញ្ញានៃការប្រើប្រាស់សម្រាប់តែការបញ្ចេញមតិយោបល់ (comments) ប៉ុណ្ណោះ ដោយគ្មានសកម្មភាពផ្ទាល់ខ្លួនជាប្រចាំនោះទេ។ ការប្រើប្រាស់ពាក្យនេះ គឺអនុលោមទៅតាមភាសាគោលនយោបាយផ្លូវការរបស់ក្រុមហ៊ុន មេតា (Meta) ដែលប្រើប្រាស់ឃ្លា «អាកប្បកិរិយាមិនពិតប្រាកដ (inauthentic behavior)» ដើម្បីពិពណ៌នាអំពីគណនីទាំងឡាយណាដែលមិនតំណាងឱ្យមនុស្សពិតប្រាកដ ឬគណនីដែលលាក់បាំងនូវគោលបំណងពិតប្រាកដនៃគណនីនោះ។

**ការបញ្ចេញមតិមិនពិតប្រាកដ (Inauthentic Comment)៖** សំដៅលើការបញ្ចេញមតិ (comment) ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលគ្នា ដើម្បីបំភាន់ ឬបង្វែរមតិសាធារណជន។ ការបញ្ចេញមតិមិនពិតប្រាកដនៅក្នុងរបាយការណ៍នេះ រួមមាន សារដែលបានរៀបចំទុកជាស្រេចដែលត្រូវបានបង្ហោះដោយគណនីជាច្រើន, សារដែលមិនស៊ីគ្នានឹងប្រធានបទនៃអត្ថបទបង្ហោះ, និងសារដែលត្រូវបានរចនាឡើងដើម្បីលើកកម្ពស់ជំហររបស់រដ្ឋាភិបាល ឬជំហរគាំទ្រក្រុមហ៊ុន ដោយអ្នកបញ្ចេញមតិទាំងនោះមិនមានភាពស្មោះត្រង់អំពីគោលបំណងពិតប្រាកដរបស់ពួកគេ។

**អាកប្បកិរិយាមិនពិតប្រាកដដែលសម្របសម្រួលគ្នា (Coordinated Inauthentic Behavior)៖** គឺជាពាក្យគន្លឹះមួយដែលត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុន មេតា (Meta) (ដែលជាក្រុមហ៊ុនមេរបស់ហ្វេសប៊ុក) ដើម្បីពិពណ៌នាអំពីករណីដែលក្រុមនៃគណនីជាច្រើនធ្វើការរួមគ្នា ដើម្បីធ្វើឱ្យសាររបស់ពួកគេមើលទៅហាក់បីដូចជាមានការពេញនិយមខ្លាំង ឬមានភាពពិតប្រាកដជាងទិដ្ឋភាពជាក់ស្តែង។ របាយការណ៍នេះប្រើប្រាស់ទស្សនទាន (concept) នេះ ដើម្បីពិពណ៌នាអំពីយុទ្ធនាការដែលមានការចាត់តាំង ដែលត្រូវបានរកឃើញនៅលើបណ្តាអង្គការនានាដែលស្ថិតក្រោមការឃ្លាំមើល។

**ពាក្យសម្តីស្អប់ខ្ពើម (Hate Speech)៖** សំដៅលើភាសាដែលវាយប្រហារទៅលើបុគ្គល ឬក្រុមណាមួយដោយផ្អែកលើអត្តសញ្ញាណរបស់ពួកគេ ដូចជា ពូជសាសន៍ សាសនា យេនឌ័រ ឬទស្សនៈនយោបាយ ក្នុងលក្ខណៈដែលអាចបង្កគ្រោះថ្នាក់ ឬជម្រុញឱ្យមានអំពើហិង្សា។ នៅក្នុងរបាយការណ៍នេះ ពាក្យសម្តីស្អប់ខ្ពើម រួមមានការគំរាមកំហែងដល់អាយុជីវិត ការអំពាវនាវឱ្យមានអំពើហិង្សា និងភាសាដែលប្រកបដោយការបន្ទាបបន្ថោកតម្លៃមនុស្ស។

**ភាសាប្រមាថ (Offensive Language)៖** សំដៅលើភាសាដែលមានលក្ខណៈទ្រគោះបោះបោក គ្មានការគោរព ឬបង្កគ្រោះថ្នាក់ ប៉ុន្តែអាចនឹងមិនទាន់ឈានដល់និយមន័យពេញលេញនៃពាក្យសម្តីស្អប់ខ្ពើមនោះទេ។ ភាសានេះរួមមាន ការជេរប្រមាថធ្ងន់ៗ ការចោទប្រកាន់មិនពិត និងភាសាដែលត្រូវបានរចនាឡើងដើម្បីធ្វើឱ្យនរណាម្នាក់មានការអៀនខ្មាស ឬរងការឈឺចាប់។

**សារគំរូ (Template Message)៖** សំដៅលើសារដែលបានរៀបចំទុកជាស្រេច ដែលត្រូវបានចម្លង (copy) និងយកទៅបង្ហោះជាច្រើនលើកច្រើនសារដោយគណនីផ្សេងៗគ្នា នៅលើអត្ថបទបង្ហោះខុសៗគ្នា។ សារគំរូគឺជាសញ្ញាមួយនៃអាកប្បកិរិយាមិនពិតប្រាកដដែលសម្របសម្រួលគ្នា ពីព្រោះមនុស្សពិតប្រាកដដែលមានមតិយោបល់ពិតប្រាកដ កម្រនឹងប្រើប្រាស់ពាក្យពេចន៍ដូចគ្នាទាំងស្រុងទៅនឹងមនុស្សជាច្រើនដទៃទៀតណាស់។

**បណ្តុំគណនី (Account Cluster)៖** សំដៅលើក្រុមដែលមានគណនីចាប់ពីពីរឡើងទៅ ដែលត្រូវបានបង្កើតឡើងក្នុងខែប្រតិទិនតែមួយនិងបង្ហាញវត្តមាននៅក្នុងផ្នែកបញ្ចេញមតិយោបល់ (comment section) តែមួយ។ បណ្តុំគណនីបង្ហាញឱ្យឃើញថា គណនីទាំងនោះត្រូវបានបង្កើតឡើងក្នុងពេលតែមួយ ដែលជាផ្នែកមួយនៃប្រតិបត្តិការដែលមានការគ្រោងទុកជាមុន។

**អសកម្មភាពស្របពេលគ្នា (Synchronized Dormancy)៖** សំដៅលើស្ថានភាពដែលក្រុមនៃគណនីទាំងអស់បញ្ឈប់ការបង្ហោះសារក្នុងពេលជាមួយគ្នាយ៉ាងជាក់លាក់។ នេះនេះគឺជាសញ្ញាមួយនៃការគ្រប់គ្រងបែបប្រមូលផ្តុំមួយកន្លែង ដែលក្នុងនោះបុគ្គលម្នាក់ ឬក្រុមមួយគ្រប់គ្រងគណនីជាច្រើន ហើយសម្រេចថាតើពេលណាដែលគណនីទាំងនោះត្រូវមានសកម្មភាព និងពេលណាដែលត្រូវបញ្ឈប់។

**គណនីឆ្លងស្ថាប័ន (Cross-Organization Account)៖** សំដៅលើគណនីដែលបង្ហាញវត្តមាននៅក្នុងផ្នែកបញ្ចេញមតិយោបល់របស់អង្គការសង្គមស៊ីវិលលើសពីមួយស្ថាប័ន។ គណនីឆ្លងស្ថាប័នគឺជាភស្តុតាងដ៏រឹងមាំមួយនៃយុទ្ធនាការដែលមានការរៀបចំទុក ពីព្រោះមនុស្សធម្មតានឹងមិនចូលទៅបញ្ចេញមតិយោបល់ជាទៀងទាត់នៅលើទំព័រ (pages) របស់អង្គការសង្គមស៊ីវិលខុសៗគ្នាជាច្រើនក្នុងពេលតែមួយនោះទេ។

**ការបំពានតាមប្រព័ន្ធអនឡាញ (Online Harassment)៖** សំដៅលើការប្រើប្រាស់បណ្តាញ ឬវេទិកាអនឡាញដើម្បីគំរាមកំហែង បំបិទមាត់ បង្ខូចកេរ្តិ៍ឈ្មោះ ឬវាយប្រហារលើបុគ្គល ឬអង្គការនានា។ នៅក្នុងរបាយការណ៍នេះ ការបំពានតាមប្រព័ន្ធអនឡាញ មិនត្រឹមតែរួមបញ្ចូលនូវការបញ្ចេញមតិយោបល់ក្នុងលក្ខណៈគំរាមកំហែង ឬជេរប្រមាថប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលទាំងយុទ្ធនាការដែលមានការរៀបចំទុក ដែលបានបង្កជា**ជំនន់មតិយោបល់**មិនពិត ដើម្បីរារាំងសាធារណជនមិនឱ្យទទួលបានព័ត៌មានពិតប្រាកដផងដែរ។

## មូលន័យសង្ខេប

របាយការណ៍នេះធ្វើការឃ្លាំមើលទំព័រហ្វេសប៊ុក (Facebook pages) របស់អង្គការសង្គមស៊ីវិលកម្ពុជាចំនួនដប់ប្រាំ ចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦។ អំឡុងពេលនៃការឃ្លាំមើលនេះ គ្របដណ្តប់លើអត្ថបទបង្ហោះសរុបចំនួន ១.៥៥៦ អត្ថបទ ដែលមានមតិយោបល់សរុបចំនួន ២៤.២៩៨។ ក្នុងចំណោមមតិយោបល់ទាំងនោះ មតិយោបល់ចំនួន ៤.៩០៣ ដែលដកស្រង់ចេញពីអត្ថបទបង្ហោះចំនួន ៥៤ នៅទូទាំងអង្គការចំនួនប្រាំមួយ ត្រូវបានជ្រើសរើសសម្រាប់ការវិភាគលម្អិតអំពីទម្រង់នៃពាក្យសម្ដីស្អប់ខ្ពើម, ភាសាប្រមាថ, និងការបញ្ចេញមតិមិនពិតប្រាកដ។ អង្គការទាំងប្រាំមួយដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគលម្អិតនោះ រួមមាន៖ សមាគមអាដហុក (Adhoc), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), អង្គការសង់ត្រាល់ (CENTRAL), អង្គការខុមហ្វ្រែល (Comfrel), អង្គការលីកាដូ (LICADHO), និងប្រជាកាសែត (ProcheaKaset) ដោយសារតែផ្នែកបញ្ចេញមតិយោបល់របស់អង្គការទាំងនេះបង្ហាញពីទម្រង់ច្បាស់លាស់នៃអាកប្បកិរិយាមិនពិតប្រាកដ។

ការរកឃើញដ៏សំខាន់គឺថា ក្រុមនៃគណនីមិនពិតប្រាកដកំពុងធ្វើការរួមគ្នាដើម្បីដៅមុខសញ្ញាទៅលើអង្គការសិទ្ធិការងារ។ គណនីទាំងនេះបង្ហោះសារដែលបានរៀបចំទុកជាស្រេច ដើម្បីបង្កជាជំនន់មតិយោបល់ និងជំរុញសារគាំទ្ររដ្ឋាភិបាល។ គណនីដដែលៗទាំងនេះ បង្ហាញវត្តមាននៅទូទាំងអង្គការខុសៗគ្នាក្នុងពេលតែមួយដែលនេះបង្ហាញឱ្យឃើញថា យុទ្ធនាការនេះគឺជាយុទ្ធនាការដែលមានការរៀបចំទុក។

យុទ្ធសាស្ត្រមិនពិតប្រាកដចំនួនប្រាំបីផ្សេងគ្នាត្រូវបានរកឃើញ រួមមាន៖ ការអះអាងថាក្រសួងរបស់រដ្ឋាភិបាលបានដោះស្រាយបញ្ហារួចរាល់ហើយ, ការផ្សព្វផ្សាយលេខទូរស័ព្ទជំនួយបន្ទាន់ផ្នែកការងារ ១២៩៧ នៅលើអត្ថបទបង្ហោះដែលមិនពាក់ព័ន្ធនឹងការងារ, ការបង្ហោះរឿងរ៉ាវផ្ទាល់ខ្លួនដែលប្រឌិតឡើង, និងការវាយប្រហារលើរបាយការណ៍ស្រាវជ្រាវដោយប្រើប្រាស់ភាសាបែបការសិក្សាស្រាវជ្រាវ។ គណនីមួយចំនួនថែមទាំងបានយកឈ្មោះរបស់អង្គការសង់ត្រាល់ (CENTRAL) ផ្ទាល់ ទៅប្រើប្រាស់ដើម្បីផ្សព្វផ្សាយសារគាំទ្ររដ្ឋាភិបាលទៀតផង។ មតិយោបល់ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត រួមទាំងការគំរាមកំហែងដល់អាយុជីវិត ត្រូវបានរកឃើញនៅលើអត្ថបទបង្ហោះរបស់សមាគមអាដហុក (Adhoc) អំពីជម្លោះដីធ្លីនៅខេត្តរតនគិរី។ អត្ថបទបង្ហោះរបស់អង្គការលីកាដូ (LICADHO) អំពីការចាប់ខ្លួនពាក់ព័ន្ធនឹងការប្រើប្រាស់បណ្ដាញសង្គម ទទួលបានការឆ្លើយតបប្រកបដោយការខឹងសម្បារយ៉ាងពិតប្រាកដជាច្រើនពីសាធារណជន។ ចំណែកឯទំព័ររបស់ប្រជាកាសែត-Prochea Kaset វិញ ទទួលបានការឆ្លើយតបពិតប្រាកដ និងគាំទ្រច្រើនបំផុតពីសំណាក់កម្មករ។

របាយការណ៍នេះផ្ដល់អនុសាសន៍ថា អង្គការនានាគួរចែករំលែកព័ត៌មានអំពីគណនីមិនពិតប្រាកដ បង្កើតប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់មតិយោបល់ និងធ្វើការរួមគ្នាដើម្បីឆ្លើយតបទៅនឹងសារមិនពិត។

## មាតិកា

**១. សេចក្តីផ្តើម ២. វិធីសាស្រ្តស្រាវជ្រាវ**

២.១ ការប្រមូលទិន្នន័យ
២.២ របៀបដែលមតិយោបល់ត្រូវបានចាត់ថ្នាក់
២.៣ របៀបដែលទម្រង់នៃការបញ្ចេញមតិមិនពិតប្រាកដត្រូវបានរកឃើញ
២.៤ កម្រិតកំណត់នៃការសិក្សា (Limitations)

**៣. ការរកឃើញទៅតាមស្ថាប័ននីមួយៗ**

៣.១ សមាគមអាដហុក (Adhoc)
៣.២ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៣.៣ អង្គការសង់ត្រាល់ (CENTRAL)
៣.៤ អង្គការខុមហ្វ្រែល (Comfrel)
៣.៥ អង្គការលីកាដូ (LICADHO)
៣.៦ ប្រជាកាសែត-Prochea Kaset

**៤. ការវិភាគឆ្លងស្ថាប័ន (Cross-Organization Analysis)**

៤.១ ក្រុមគណនីមិនពិតប្រាកដធ្វើការរួមគ្នា
៤.២ យុទ្ធសាស្រ្តដែលបានប្រើប្រាស់
៤.៣ ភស្តុតាងនៃសារដែលបានរៀបចំទុកជាស្រេច
៤.៤ ការវិភាគបណ្តាញគណនី (Account Network Analysis)

**៥. ការពិភាក្សា**
**៦. សន្និដ្ឋាន**
**៧. អនុសាសន៍**

# ១. សេចក្តីផ្តើម

បច្ចុប្បន្ននេះ ហ្វេសប៊ុក (Facebook) គឺជាមធ្យោបាយចម្បងដែលក្រុមសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ប្រើប្រាស់ដើម្បីចែករំលែកព័ត៌មាន និងជជែកពិភាក្សាជាមួយសាធារណជន។ ប៉ុន្តែ ហ្វេសប៊ុកក៏ត្រូវបានប្រើប្រាស់ដោយក្រុមដែលមានការរៀបចំចាត់តាំង ដើម្បីវាយប្រហារ និងបង្ខូចកេរ្តិ៍ឈ្មោះសង្គមស៊ីវិលផងដែរ។ ហេតុការណ៍នេះកើតឡើងតាមរយៈការបញ្ចេញមតិមិនពិតប្រាកដ ការផ្ញើសារដដែលៗ និងយុទ្ធនាការដែលមានការរៀបចំទុក។

របាយការណ៍នេះគ្របដណ្តប់លើចន្លោះពេលចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦។ ក្នុងអំឡុងពេលនេះ ព្រឹត្តិការណ៍សំខាន់ៗជាច្រើនបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ព្រឹត្តិការណ៍ទាំងនោះរួមមាន ជម្លោះព្រំដែនរវាងកម្ពុជានិងថៃ ដែលបានបង្ខំឱ្យពលករកម្ពុជាជាច្រើននាក់ត្រូវត្រឡប់មកផ្ទះវិញ ព្រមទាំងបាត់បង់ដីស្រែចំការ និងផ្ទះសម្បែងរបស់ពួកគេ។ ក្រៅពីនេះ ក៏មានការតវ៉ានៅតាមរោងចក្រនានាពាក់ព័ន្ធនឹងការមិនបើកប្រាក់ឈ្នួល និងការបាត់បង់ការងារធ្វើផងដែរ។ មនុស្សមួយចំនួនត្រូវបានចាប់ខ្លួន និងបញ្ជូនទៅពន្ធនាគារ ដោយសារតែការបង្ហោះសារនៅលើហ្វេសប៊ុក (Facebook) អំពីបញ្ហាព្រំដែន។

របាយការណ៍នេះធ្វើការឃ្លាំមើលអង្គការសង្គមស៊ីវិលចំនួនដប់ប្រាំ។ ក្នុងចំណោមអង្គការទាំងនោះ អង្គការចំនួនប្រាំមួយត្រូវបានជ្រើសរើសសម្រាប់ការវិភាគមតិយោបល់យ៉ាងលម្អិត ដោយសារតែផ្នែកបញ្ចេញមតិយោបល់របស់ពួកគេបង្ហាញពីទម្រង់ច្បាស់លាស់នៃអាកប្បកិរិយាមិនពិតប្រាកដ។ អង្គការទាំងប្រាំមួយនេះរួមមានៈ សមាគមអាដហុក (Adhoc), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), អង្គការសង់ត្រាល់ (CENTRAL), អង្គការខុមហ្វ្រែល (Comfrel), អង្គការលីកាដូ (LICADHO), និងប្រជាកាសែត-Prochea Kaset។ សរុបរួមមក អត្ថបទបង្ហោះនៅលើហ្វេសប៊ុករបស់អង្គការទាំងនេះ ទទួលបានមតិយោបល់ចំនួន ៤.៩០៣ នៅទូទាំងអត្ថបទបង្ហោះចំនួន ៥៤ ដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគលម្អិត។ គោលបំណងនៃរបាយការណ៍នេះគឺ៖

- ដើម្បីកត់ត្រាទុកជាឯកសារនូវពាក្យសម្ដីស្អប់ខ្ពើម និងភាសាប្រមាថ ដែលដៅមុខសញ្ញាលើអង្គការសង្គមស៊ីវិល។
- ដើម្បីស្វែងរកទម្រង់នៃការបញ្ចេញមតិមិនពិតប្រាកដ ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងធ្វើឱ្យសាធារណជនមានការភាន់ច្រឡំ ឬដើម្បីបំបិទសំឡេងពួកគេ។
- ដើម្បីផ្តល់ព័ត៌មានដែលមានប្រយោជន៍ ក្នុងការជួយដល់សមាជិកនៃអង្គការសង្គមស៊ីវិល ឱ្យយល់ដឹងកាន់តែច្បាស់ និងអាចឆ្លើយតបទៅនឹងការបំពានតាមប្រព័ន្ធអនឡាញ ដែលដៅមុខសញ្ញាលើការងាររបស់ពួកគេ។

# ២. វិធីសាស្ត្រស្រាវជ្រាវ

## ២.១ ការប្រមូលទិន្នន័យ

ក្នុងអំឡុងពេលនៃការឃ្លាំមើលចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦ ការសិក្សានេះបានធ្វើការឃ្លាំមើលទំព័រហ្វេសប៊ុក (Facebook pages) របស់អង្គការសង្គមស៊ីវិលកម្ពុជាចំនួនដប់ប្រាំ។ ទិន្នន័យនៃអត្ថបទបង្ហោះ និងមតិយោបល់នៅលើហ្វេសប៊ុក ត្រូវបានប្រមូលសម្រាប់អង្គការនីមួយៗ។ តារាងខាងក្រោមនេះបង្ហាញពីអង្គការទាំងអស់ដែលត្រូវបានឃ្លាំមើល រួមជាមួយនឹងចំនួនអត្ថបទបង្ហោះ និងមតិយោបល់សរុបដែលត្រូវបានកត់ត្រាទុកក្នុងអំឡុងពេលនោះ៖

| **អង្គការ** | **អត្ថបទបង្ហោះ** | **មតិយោបល់** | **ប្រធានបទសំខាន់ៗ** |
|---|---|---|---|
| សមាគមអាដហុក (Adhoc) | ៣ | ៥៨៧ | ជម្លោះដីធ្លី, ការងារ, ការធ្វើកូដកម្មណាហ្គាវើលដ៍ |
| មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | ១ | ៣៥ | ការធ្វើកូដកម្មរបស់សហជីព LRSU នៃក្រុមហ៊ុនណាហ្គាវើលដ៍ |
| អង្គការសង់ត្រាល់ (CENTRAL) | ៤១ | ~១,៦១៩ | ការធ្វើចំណាកស្រុក, ជម្លោះការងារ, ការស្រាវជ្រាវ, ការអប់រំ |
| អង្គការខុមហ្វ្រែល (Comfrel) | ៤ | ៣៧២ | ពលករចំណាកស្រុក, ការធ្វើកូដកម្មនៅតាមរោងចក្រ |
| អង្គការលីកាដូ (LICADHO) | ៤ | ២,៣៨៤ | ការចាប់ខ្លួនពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិ |
| ប្រជាកាសែត-Prochea Kaset | ១ | ៩០៥ | កម្មកររោងចក្រដែលទទួលបានប្រាក់ឈ្នួលអប្បបរិមា |
| **សរុប** | **៥៤** | **៤,៩០៣** | |

*តារាងទី១៖ សេចក្ដីសង្ខេបនៃអត្ថបទបង្ហោះ និងមតិយោបល់ដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគលម្អិត*

| **អង្គការ** | **ចំនួនអត្ថបទបង្ហោះសរុប** | **ចំនួនមតិយោបល់សរុប** | **ចំនួនអត្ថបទបង្ហោះត្រូវបានវិភាគ** | **ចំនួនមតិយោបល់ត្រូវបានវិភាគ** |
|---|---|---|---|---|
| សមាគមអាដហុក (Adhoc) | ៧៩ | ១,៤៤៧ | ៣ | ៥៨៧ |
| សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) | ៥៦ | ៣៥១ | ០ | ០ |

| | | | | |
|---|---|---|---|---|
| មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | ១១៩ | ៣១០ | ១ | ៣៥ |
| មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) | ៩២ | ១១០ | ០ | ០ |
| អង្គការសង់ត្រាល់ (CENTRAL) | ១៩០ | ២,៦៦៤ | ៤១ | ~១,៦១៩ |
| សហព័ន្ធកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF) | ៥២ | ៥ | ០ | ០ |
| អង្គការខុមហ្វ្រែល (Comfrel) | ៣០៦ | ១,៦១៦ | ៤ | ៣៧២ |
| សមាគមបណ្តាញយុវជនកម្ពុជា (CYN) | ៧៨ | ២១៤ | ០ | ០ |
| សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) | ២១ | ៦២ | ០ | ០ |
| អង្គការ ក្លាហា-Klahaan | ៧៧ | ១១០ | ០ | ០ |
| អង្គការលីកាដូ (LICADHO) | ១០២ | ៦,៧៨៨ | ៤ | ២,៣៨៥ |
| សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ - LRSU | ១៥ | ៧៥ | ០ | ០ |
| អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ PED | ៤២ | ៨១៤ | ០ | ០ |
| ប្រជាកាសែត-Prochea Kaset | ៣០១ | ៨,៩៦៧ | ១ | ៩០៥ |
| សមាគមធាងត្នោត(STT) | ១៦ | ២១ | ០ | ០ |
| សរុប | ១,៥៤៦ | ២៣,៥៥៤ | ៥៤ | ៤,៩០៣ |

*តារាងទី២៖ អង្គការដែលត្រូវបានឃ្លាំមើលនៅលើហ្វេសប៊ុក ចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦*

តារាងខាងលើបង្ហាញពីអង្គការសង្គមស៊ីវិលទាំងដប់ប្រាំ ដែលត្រូវបានឃ្លាំមើលនៅក្នុងការសិក្សានេះ ចាប់ពីខែកុម្ភៈ ដល់ខែមេស ឆ្នាំ២០២៦។

អង្គការទាំងដប់ប្រាំត្រូវបានឃ្លាំមើលលើអត្ថបទបង្ហោះនៅលើហ្វេសប៊ុករបស់ពួកគេក្នុងអំឡុងពេលនេះ។ ទោះជាយ៉ាងណាក៏ដោយ មានតែអង្គការចំនួនប្រាំមួយប៉ុណ្ណោះដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគមតិយោបល់យ៉ាងលម្អិត រួមមាន៖ សមាគមអាដហុក (Adhoc), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), អង្គការសង់ត្រាល់ (CENTRAL), អង្គការខុមហ្វ្រែល (Comfrel), អង្គការលីកាដូ (LICADHO), និងប្រជាកាសែត-Prochea Kaset។ អង្គការទាំងប្រាំមួយនេះត្រូវបានជ្រើសរើសដោយសារតែផ្នែកបញ្ចេញមតិយោបល់របស់ពួកគេបង្ហាញពីទម្រង់ច្បាស់លាស់នៃអាកប្បកិរិយាមិនពិតប្រាកដ។ ចំណែកឯអង្គការចំនួន

ប្រាំបួនដែលនៅសេសសល់ មិនបានបង្ហាញពីទម្រង់បែបនេះទេ ហេតុទើបមិនត្រូវបានយកមកធ្វើការវិភាគបន្ត។ មតិយោបល់សរុបចំនួន ៤.៩០៣ ដែលដកស្រង់ចេញពីអត្ថបទបង្ហោះចំនួន ៥៤ នៅទូទាំងអង្គការដែលបានជ្រើសរើសទាំងប្រាំមួយ ត្រូវបានយកមកវិភាគដើម្បីស្វែងរកពាក្យសម្ដីស្អប់ខ្ពើម, ភាសាប្រមាថ, និងទម្រង់នៃការបញ្ចេញមតិមិនពិតប្រាកដ។

## ២.២ ការចាត់ថ្នាក់មតិយោបល់

មតិយោបល់នីមួយៗត្រូវបានចាត់ថ្នាក់ទៅជាកម្រិតមួយក្នុងចំណោមកម្រិតទាំងបួន ដោយផ្អែកលើកម្រិតធ្ងន់ធ្ងរនៃភាសាដែលបានប្រើប្រាស់៖

| កម្រិត | **ប្រភេទ** | **អត្ថន័យ** |
|---|---|---|
| ខ្ពស់ | ការគំរាមកំហែងដល់អាយុជីវិត, ពាក្យសម្ដីស្អប់ខ្ពើមពូជសាសន៍ | ការអំពាវនាវដោយផ្ទាល់ឱ្យមានការសម្លាប់, ការប្រៀបប្រដូចក្រុមជាតិពន្ធុទៅនឹងសត្វ, ការលើកឡើងអំពីអំពើហិង្សាផ្លូវភេទទូទៅ។ |
| មធ្យម | ការជេរប្រមាថធ្ងន់ធ្ងរ, ភាសាប្រមាថ | ការប្រើប្រាស់ភាសាអាក្រក់ និងធ្ងន់ធ្ងរដែលដៅចំលើបុគ្គល ឬអង្គការ, ការចោទប្រកាន់មិនពិត, ការអំពាវនាវឱ្យបិទក្រុមសង្គមស៊ីវិល។ |
| ទាប | ការជេរប្រមាថស្រាលៗ, មតិយោបល់ក្នុងន័យច្រានចោល/មិនខ្វល់ខ្វាយ | ការប្រើប្រាស់ភាសាអាក្រក់កម្រិតស្រាល, ការចោទប្រកាន់ទូទៅថាកំពុងធ្វើប្រូភាកង់ដា (ការឃោសនាអកុសល), ការច្រានចោលឬមិនខ្វល់ខ្វាយពីកម្មករដោយគ្មានការវាយប្រហារជាក់លាក់ណាមួយ។ |
| មតិយោបល់ធម្មតា | គ្មានពាក្យសម្ដីស្អប់ខ្ពើម | គ្មានពាក្យសម្ដីស្អប់ខ្ពើម។ មតិយោបល់នោះអាចនឹងនៅតែជាផ្នែកមួយនៃយុទ្ធនាការមិនពិតប្រាកដ។ |

*តារាងទី៣៖ កម្រិតនៃការចាត់ថ្នាក់មតិយោបល់ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សានេះ*

## ២.៣ ការរកឃើញនូវទម្រង់នៃការបញ្ចេញមតិមិនពិតប្រាកដ

មតិយោបល់ទាំងនោះក៏ត្រូវបានពិនិត្យផងដែរ ដើម្បីស្វែងរកទម្រង់មិនពិតប្រាកដ។ ទាំងនេះគឺជាមតិយោបល់ដែលព្យាយាមធ្វើឱ្យមានការភាន់ច្រឡំ បំបិទសំឡេង ឬរុញច្រានប្រឆាំងនឹងការបង្ហោះរបស់សង្គមស៊ីវិល ដោយមិនប្រើប្រាស់ពាក្យសម្ដីស្អប់ខ្ពើម។ ប្រភេទនៃទម្រង់មិនពិតប្រាកដដូចខាងក្រោមនេះត្រូវបានរកឃើញ៖

- ការប្រើប្រាស់សារគាំទ្ររដ្ឋាភិបាល (Pro-Government Narrative)៖ មតិយោបល់ដែលលើកឡើងថាក្រសួងរបស់រដ្ឋាភិបាលបានដោះស្រាយបញ្ហានោះរួចរាល់ហើយ។
- ការសម្រុកបង្ហោះលេខទូរស័ព្ទបន្ទាន់រកការងារធ្វើ (Job Hotline Flooding)៖ មតិយោបល់ជាច្រើនដែលផ្សព្វផ្សាយអំពីលេខទូរស័ព្ទរកការងារធ្វើរបស់រដ្ឋាភិបាលគឺលេខ ១២៩៧ ឬ ១២៨៦ នៅលើការបង្ហោះនានាដែលមិនពាក់ព័ន្ធនឹងរឿងការងារ។
- រឿងរ៉ាវផ្ទាល់ខ្លួនមិនពិតប្រាកដ (Inauthentic Personal Stories)៖ រឿងរ៉ាវផ្ទាល់ខ្លួនដែលត្រូវបានប្រឌិតឡើងអំពីការស្វែងរកការងារធ្វើបានតាមរយៈរដ្ឋាភិបាល។ រឿងរ៉ាវទាំងនេះអាចសម្គាល់បានដោយសារតែអត្ថបទដូចគ្នាបេះបិទត្រូវបានបង្ហាញនៅលើការបង្ហោះជាច្រើនដោយគណនីខុសៗគ្នាដែលវាមិនអាចទៅរួចឡើយសម្រាប់បទពិសោធន៍ផ្ទាល់ខ្លួនពិតប្រាកដ។
- ការរិះគន់ការស្រាវជ្រាវបែបមិនពិតប្រាកដ (Inauthentic Research Criticism)៖ ការប្រើប្រាស់ពាក្យពេចន៍ដែលស្តាប់ទៅដូចជាការរិះគន់បែបសិក្សាស្រាវជ្រាវ ដើម្បីធ្វើឱ្យរបាយការណ៍ស្រាវជ្រាវនានាមើលទៅហាក់ដូចជាមិនគួរឱ្យទុកចិត្ត។
- ការយកឈ្មោះអង្គការមកប្រើប្រាស់៖ ការយកឈ្មោះរបស់អង្គការសង់ត្រាល់ (CENTRAL) មកប្រើប្រាស់ក្នុងមតិយោបល់ ដើម្បីធ្វើឱ្យមើលទៅហាក់ដូចជាអង្គការ CENTRAL ខ្លួនឯងកំពុងផ្សព្វផ្សាយសាររបស់រដ្ឋាភិបាល។
- មតិយោបល់ដូចគ្នាបេះបិទ (Duplicate Comments)៖ សារដូចគ្នាបេះបិទដែលត្រូវបានបង្ហោះដោយគណនីខុសៗគ្នាជាច្រើននៅលើអត្ថបទបង្ហោះតែមួយ។
- ទម្រង់សារគំរូឆ្លងកាត់ការបង្ហោះ (Cross-Post Templates)៖ សារដែលបានរៀបចំទុកជាស្រេចដូចៗគ្នា ដែលត្រូវបានយកទៅប្រើប្រាស់នៅលើអត្ថបទបង្ហោះខុសៗគ្នាជាច្រើននៅថ្ងៃផ្សេងៗគ្នា។
- ការប្រើប្រាស់សុភាសិតប្រឆាំងនឹងការផ្តល់ជំនួយ៖ ការប្រើប្រាស់ពាក្យស្លោក "បង្រៀនមនុស្សឱ្យចេះស្ទូចត្រី" ដើម្បីជជែកវែកញែកថាការផ្តល់អាហារដល់ប្រជាពលរដ្ឋដែលផ្លាស់ប្តូរទីលំនៅគឺជាជម្រើសមិនល្អ។

មតិយោបល់ដូចគ្នាបេះបិទត្រូវបានពិនិត្យមើលពីរម្រិតផ្សេងគ្នា។ ពាក្យថា «ក្នុងអត្ថបទបង្ហោះតែមួយ» (Within-post) មានន័យថាសារដូចគ្នាបេះបិទបានបង្ហាញឡើងពីគណនីខុសៗគ្នានៅលើអត្ថបទបង្ហោះតែមួយគត់។ ចំណែកឯ «ការបង្ហោះឆ្លងទៅផុសផ្សេង» (Cross-post) មានន័យថាសារដូចគ្នាបេះបិទនោះបានបង្ហាញនៅលើអត្ថបទបង្ហោះខុសៗគ្នាជាច្រើន។ ការរកឃើញមតិយោបល់ដូចគ្នាបេះបិទបែបការបង្ហោះឆ្លងទៅផុសផ្សេងនេះ គឺជាភស្តុតាងយ៉ាងរឹងមាំដែលបញ្ជាក់ពីការមានបញ្ជីសារដែលបានរៀបចំទុកជាស្រេច។

ការប្រើប្រាស់ វិធាននៃការមិនសកម្ម (inactivity rule) ដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សានេះ គឺអាចស្វែងរកឃើញគណនីមិនពិតប្រាកដមួយប្រភេទ។ គណនីមិនពិតប្រាកដ ទាំងនេះគឺជាគណនីដែលត្រូវបានបង្កើតឡើងជាក្រុមៗ ហើយបន្ទាប់មកបានឈប់បង្ហោះសកម្មភាពអ្វីទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានេះក៏បានរកឃើញនូវគណនីដែលទើបតែបង្កើតថ្មីៗ ហើយដែលនៅតែមានបន្តសកម្មភាពនៅឡើយ មានន័យថាការបច្ចុប្បន្នភាពចុងក្រោយបង្អស់របស់ពួកគេគឺមានរយៈពេលតិចជាងបួនសប្តាហ៍មុន។ គណនីសកម្មទាំងនេះក៏បង្ហាញសញ្ញានៃការជាគណនីមិនពិតប្រាកដផងដែរ ដោយសារតែមតិយោបល់របស់ពួកគេគឺត្រូវគ្នាបេះបិទទៅនឹងសារដែលបានរៀបចំទុកជាស្រេច ដែលបានបង្ហាញឡើងនៅលើអត្ថបទបង្ហោះជាច្រើន ឬនៅ

តាមអង្គការខុសៗគ្នា។ គណនីទាំងនេះមិនត្រូវបានចាប់បានដោយវិធីសាស្ត្រប្រើប្រាស់ទង់សម្គាល់ពីរ (two-flag method) ដែលបានពិពណ៌នាខាងលើនោះទេ។ ការវិភាគលើមតិយោបល់ដែលត្រូវគ្នាបេះបិទនៅក្នុងផ្នែកទី ៤.១ និង ៤.៣ គឺគ្របដណ្តប់លើគណនីមិនពិតប្រាកដប្រភេទទីពីរនេះ។

### ២.៤ កម្រិតកំណត់នៃការសិក្សា

ការសិក្សានេះគ្របដណ្តប់តែលើអត្ថបទបង្ហោះដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគតែប៉ុណ្ណោះ។ មិនមែនគ្រប់អត្ថបទបង្ហោះទាំងអស់របស់អង្គការនីមួយៗត្រូវបានយកមកវិភាគនោះទេ។ គណនីមិនពិតប្រាកដដែលត្រូវបានរកឃើញនៅក្នុងការសិក្សានេះ បង្ហាញពីសញ្ញានៃអាកប្បកិរិយាដែលមានការចាត់តាំងជាប្រព័ន្ធ (coordinated behavior) ប៉ុន្តែការសិក្សានេះមិនអាចបញ្ជាក់បានថា នរណាជាអ្នកនៅពីក្រោយការចាត់តាំងជាប្រព័ន្ធនេះឡើយ។

## ៣. លទ្ធផលនៃការរកឃើញតាមអង្គការនីមួយៗ

### ៣.១ សមាគមអាដហុក (Adhoc)

***ទិដ្ឋភាពទូទៅ***

អត្ថបទបង្ហោះចំនួនបីពីសមាគមអាដហុក ត្រូវបានយកមកវិភាគ ដោយមានមតិយោបល់សរុបចំនួន ៥៨៧។ អត្ថបទបង្ហោះទី១ គឺស្តីអំពីការហែក្បួនរបស់កម្មករក្នុងទិវាអន្តរជាតិនារី (មាន ២៥ មតិយោបល់)។ អត្ថបទបង្ហោះទី២ គឺស្តីអំពីការចាប់ខ្លួនសកម្មជន សឿន កេត នៅក្នុងជម្លោះដីធ្លីមួយនៅខេត្តរតនគិរី ដែលពាក់ព័ន្ធនឹងក្រុមគ្រួសារជនជាតិដើមភាគតិច (មាន ៥៣៥ មតិយោបល់)។ អត្ថបទបង្ហោះទី៣ គឺស្តីអំពីឆ្នាំទីបួននៃការធ្វើកូដកម្មរបស់កម្មករកាស៊ីណូណាហ្គាវើលដ៍ (មាន ២៧ មតិយោបល់)។

| អត្ថបទបង្ហោះ | មតិយោបល់ | សញ្ញាណរកឃើញ | ខ្ពស់ | មធ្យម | មិនមានពាក្យសម្តីស្អប់ខ្ពើម |
|---|---|---|---|---|---|
| អត្ថបទបង្ហោះទី១៖ ការហែក្បួនទិវាពលកម្មអន្តរជាតិ | ២៥ | ០ | ០ | ០ | ២៥ |
| អត្ថបទបង្ហោះទី២៖ ដីធ្លីនៅខេត្តរតនគិរី / ការចាប់ខ្លួនលោក សឿន កេត | ៥៣៥ | ៧៤ | ១៧ | ៥៧ | ៤៦១ |
| អត្ថបទបង្ហោះទី៣៖ ខួបនៃការធ្វើកូដកម្មក្រុមហ៊ុនណាហ្គាវើលដ៍ | ២៧ | ០ | ០ | ០ | ២៧ |
| **សរុប** | **៥៨៧** | **៧៤** | **១៧** | **៥៧** | **៥១៣** |

*តារាងទី៤ក៖ ការវិភាគលើខ្លឹមសារពាក្យសម្តីខ្ពើមដោយការអត្ថបទបង្ហោះ (Adhoc)*

| **អត្ថបទបង្ហោះ** | **មតិយោបល់** | **សញ្ញាណរកឃើញ** | **លំនាំភាពមិនពិតប្រាកដ** | **ភាពពិតប្រាកដ** | **អត្រាភាពមិនពិតប្រាកដ** |
|---|---|---|---|---|---|
| អត្ថបទបង្ហោះទី១៖ ការហែក្បួនទិវាពលកម្មអន្តរជាតិ | ២៥ | 0 | 0 | ២៥ | 0% |
| អត្ថបទបង្ហោះទី២៖ ដីធ្លីនៅខេត្តរតនគិរី / ការចាប់ខ្លួនលោក សឿន កេត | ៥៣៥ | 0 | 0 | ៥៣៥ | 0% |
| អត្ថបទបង្ហោះទី៣៖ ខួបនៃការធ្វើកូដកម្មក្រុមហ៊ុនណាហ្គាវើលដ៍ | ២៧ | 0 | 0 | ២៧ | 0% |
| **សរុប** | **៥៨៧** | **0** | **0** | **៥៨៧** | **0%** |

*តារាងទី៤ខ៖ ការវិភាគបណ្ដោះអាសន្នលើយុទ្ធនាការមិនប្រក្រតីតាមរយៈអត្ថបទបង្ហោះ*

### *លទ្ធផលរកឃើញសំខាន់ៗ*

អត្ថបទបង្ហោះទី២ ដែលបានរាយការណ៍អំពីជម្លោះដីធ្លីនៅខេត្តរតនគិរី និងការចាប់ខ្លួនលោក សឿន កេត មានពាក្យសម្ដីស្អប់ខ្ពើមធ្ងន់ធ្ងរបំផុតក្នុងចំណោមអត្ថបទបង្ហោះទាំងអស់នៅក្នុងការសិក្សានេះ។ មតិយោបល់ចំនួនដប់ពីរស្ថិតនៅក្នុង «កម្រិតធ្ងន់ធ្ងរខ្លាំង»។ មតិយោបល់ទាំងនេះភាគច្រើន គឺជាការអំពាវនាវដោយផ្ទាល់ឱ្យមានអំពើហិង្សាប្រឆាំងនឹងបុគ្គលដែលគេមើលឃើញថាជាអ្នកពាក់ព័ន្ធនឹងការរំលោភយកដីធ្លី។ មតិយោបល់ចំនួន ៥៧ ផ្សេងទៀតបានប្រើប្រាស់ភាសាកម្រិតមធ្យម រួមមានការចោទប្រកាន់ពីបទពុករលួយ, ភាសាប្រឆាំងនឹងជនជាតិថៃ, និងភាសាបង្ខូចតម្លៃមនុស្សដោយហៅមន្ត្រីថា «ឆ្កែ»។ ចំណែកឯអត្ថបទបង្ហោះទី១ និងអត្ថបទបង្ហោះទី៣ មានមតិយោបល់ធ្ងន់ធ្ងរតិចតួចបំផុត។ គ្មានយុទ្ធនាការមិនពិតប្រាកដដែលមានការចាត់តាំងណាមួយ ត្រូវបានរកឃើញនៅលើអត្ថបទបង្ហោះរបស់សមាគមអាដហុកក្នុងអំឡុងត្រីមាសនេះឡើយ។

### ឧទាហរណ៍នៃមតិយោបល់

| **មតិយោបល់ដើម** |
|---|
| វ៉ៃវ៉ៃវាសម្លាប់ទៅ |
| សម្លាប់វាចោលទៅ |
| កាប់វាអោយងាប់បង |
| នាំគ្នាកាប់ក្បាលចោរអាបែកទៅ |
| យកកាំបិតកាបក្បាល់ពួកឲ្យងាប់អស់ទៅពួកអាក្បត់ជាតិ |
| ពេលនេះគឺមិនបាច់ស្រែកដង្ហយយំទៀតទេ។មានដំបងវ៉ៃយក្បាលវាទៅគឺរឿងមួយក៏មានកាំបិតកាប់ក្បាលវាទៅ។ចប់រឿងហើយ។ |
| ថៃវ៉ៃយកដីអស់ហើយមិនគិតទេគិតអ្វីគ្នាហ្នឹង |

| |
|---|
| ចោរសៀមយកដីប្រជាពលរដ្ឋនិងផ្ទះតាមព្រំដែន មន្ត្រីឆ្កែរបបហូនសែនយកដីប្រជាពលរដ្ឋតាមខេត្ត មិនដោះស្រាយចាប់ជាពលរដ្ឋថែមទៀត។ |
| ព្រំដែនមិនទៅកាពារដេញចោរឈ្លានពានទឹកដីទេមកធ្វើបាបប្រជាជន កន្ទួយម៉ើរាអាឆ្កែ |
| មន្ត្រីរាជឆ្កែខាំរាស្ត្រទាំងព្រលឹម |

## ៣.២ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

### *ទិដ្ឋភាពទូទៅ*

អត្ថបទបង្ហោះចំនួនមួយពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ត្រូវបានយកមកវិភាគ ដែលស្តីអំពីការធ្វើកូដកម្មរបស់សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU) ក្នុងថ្ងៃទី ១.៥៥៨ (ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២៦)។ ការបង្ហោះនោះមានមតិយោបល់ចំនួន ៣៥។

| អត្ថបទបង្ហោះ | មតិយោបល់ | សញ្ញាណរកឃើញ | ខ្ពស់ | មធ្យម | ទាប | មិនមានពាក្យសម្តីស្អប់ខ្ពើម |
|---|---|---|---|---|---|---|
| ថ្ងៃទី ១,៥៥៨ នៃការធ្វើកូដកម្មរបស់សហជីព LRSU នៃក្រុមហ៊ុនណាហ្គាវើលដ៍ | ៣៥ | ៩ | ០ | ៦ | ៣ | ២០ |

*តារាងទី៥កៈ CCHR, ការវិភាគខ្លឹមសារស្អប់ខ្ពើមតាមរយៈអត្ថបទបង្ហោះ*

| អត្ថបទបង្ហោះ | មតិយោបល់ | សញ្ញាណរកឃើញ | លំនាំភាពមិនពិតប្រាកដ | ភាពពិតប្រាកដ | អត្រាភាពមិនពិតប្រាកដ |
|---|---|---|---|---|---|
| ទី ១,៥៥៨ នៃការធ្វើកូដកម្មរបស់សហជីព LRSU នៃក្រុមហ៊ុនណាហ្គាវើលដ៍ | ៣៥ | ៩ | ៣០ | ៥ | ៨៦% |

*តារាងទី៥ខៈ CCHR, ការវិភាគយុទ្ធនាការមិនប្រក្រតីតាមរយៈអត្ថបទបង្ហោះ*

### ឧទាហរណ៍នៃមតិយោបល់

| មតិយោបល់ដើម |
|---|
| ខ្ញុំកម្មករម្នាក់ តាមខ្ញុំដឹង ក្រសួងតែងចេញមុខជួយជានិច្ចមិនដែលលម្អៀងទៅភាគីថៅកែឡើយ |
| គេដោះស្រាយឱ្យហើយ តែយើងទេដែលមិនព្រមទទួលលទ្ធផល |
| បើចង់ដោះស្រាយ សូមទៅតុលាការដើម្បីដោះស្រាយ |

| | |
|---|
| ប្រសិនជាអ្នកធ្វើការណាហ្គាវើលដ៏មិនមានសហជីពរឹងទទឹងសលុយបរទេសនោះទេ<br>ប្រហែលជាបងប្អូនកម្មករមានដំណោះស្រាយល្អប្រសើរបាត់ទៅហើយ |
| ការចោទប្រកាន់របស់ក្រុមសហជីពប៉ុន្មានអ្នកនេះ គឺមិនពិតនោះទេ ព្រោះសហជីពគេផ្សេងគោរពច្បាប់ |
| មកហើយចង់មកទៀត ការពិតអ្នកឯងធ្វើការតាមខ្សែញាក់បរទេសទេ |
| រឿងដដែលៗស្មា នតែរឿងថ្មីតាមការពិតពួកឯងបន្លំមតិសាធារណៈ |
| សហជីពដែលធ្វើខុសច្បាប់ត្រូវទទួលទោសតាមច្បាប់ |
| តើកញ្ញាហ៊ានទទួលឬបញ្ជាក់ ដែលទេចា លុយបានមកពីបរទេសជួលមកអោយនិយាយបង្ខូចឈ្មោះ |

### *លទ្ធផលរកឃើញសំខាន់ៗ*

ទោះបីជាអត្ថបទបង្ហោះរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) មានមតិយោបល់ត្រឹមតែ ៣៥ ក៏ដោយ វាបានបង្ហាញយ៉ាងច្បាស់អំពីរបៀបដែលយុទ្ធនាការចាត់តាំងដំណើរការ។ មតិយោបល់ចំនួនប្រាំពីរបានប្រើប្រាស់ទម្រង់មិនពិតប្រាកដ។ ទម្រង់ទាំងនេះរួមមាន៖ ការលើកឡើងថាក្រសួងការងារបានដោះស្រាយករណីនេះរួចរាល់ហើយ, ការនិយាយថាសហជីពទទួលបានប្រាក់ឈ្នួលពីអង្គការបរទេស, ការគាំទ្រក្រុមហ៊ុនជំនួសឱ្យការគាំទ្រកម្មករ, ការប្រាប់កម្មករឱ្យទៅដោះស្រាយនៅតុលាការជំនួសឱ្យការធ្វើការតវ៉ា, និងការប្រើប្រាស់គណនីខុសគ្នាពីរបង្ហោះសារដូចគ្នាបេះបិទដើម្បីវាយប្រហារសហជីព។ នៅពេលពិនិត្យមើលមតិយោបល់ទាំង ៣៥ ជារួម មានមតិយោបល់ចំនួន ៣០ (ស្មើនឹង ៨៦ ភាគរយ) ដែលបានបង្ហាញសញ្ញានៃយុទ្ធនាការមិនពិតប្រាកដ។ នេះបង្ហាញឱ្យឃើញថាសូម្បីតែនៅលើអត្ថបទបង្ហោះដែលមានមតិយោបល់តិចតួចក៏ដោយ ក៏យុទ្ធនាការនេះនៅតែមានសកម្មភាពយ៉ាងខ្លាំងក្លា និងដៅចំគោលដៅលើអង្គការសង្គមស៊ីវិលជាក់លាក់ណាមួយ។

## ៣.៣ អង្គការសង់ត្រាល់ (CENTRAL)

### *ទិដ្ឋភាពទូទៅ*

នៅពេលដែលអង្គការសង់ត្រាល់ (CENTRAL) រាយការណ៍អំពីការតវ៉ានៅតាមរោងចក្រ ឬជម្លោះកម្មករ ផ្នែកមតិយោបល់ត្រូវបានបំពេញយ៉ាងឆាប់រហ័សដោយសារនានាដែលលើកឡើងថាក្រសួងបានដោះស្រាយបញ្ហានោះរួចរាល់ហើយ។ នៅលើអត្ថបទបង្ហោះអំពីដោះស្រាយវិវាទការងារនៅរោងចក្រកាត់ដេរ ហិន ៧ (Hen 7 Garment) មតិយោបល់រហូតដល់ទៅ ៩៤ ភាគរយ គឺជាប្រភេទសារទាំងនេះ។ គណនីទាំងនោះក៏បានប្រាប់អ្នកអានកុំឱ្យបន្តចែកចាយព័ត៌មាននោះទៀតផងដែរ ដោយសារតែករណីនេះត្រូវបានដោះស្រាយរួចហើយ។ យុទ្ធសាស្ត្រនេះមានគោលបំណងបញ្ឈប់សាធារណជនកុំឱ្យមានការព្រួយបារម្ភអំពីជម្លោះការងារដែលកំពុងបន្តកើតមាន។

### *យុទ្ធសាស្ត្រទី១៖ «ក្រសួងបានដោះស្រាយរួចរាល់ហើយ»*

នៅពេលដែលអង្គការសង់ត្រាល់ (CENTRAL) រាយការណ៍អំពីការតវ៉ានៅតាមរោងចក្រ ឬជម្លោះកម្មករ ផ្នែកមតិយោបល់ត្រូវបានសរសេរបង្ហោះយ៉ាងឆាប់រហ័សដោយសារនានាដែលលើកឡើងថាក្រសួងបានដោះស្រាយបញ្ហានោះរួចរាល់ហើយ។ នៅលើអត្ថបទបង្ហោះអំពីដំណោះស្រាយវិវាទការងារនៅរោងចក្រកាត់ដេរ ហិន ៧ (Hen 7 Garment) មតិយោបល់រហូតដល់ទៅ ៩៤ ភាគរយ គឺជាប្រភេទសារទាំងនេះ។ គណនីទាំង

នោះក៏បានប្រាប់អ្នកអានកុំឱ្យបន្តចែកចាយព័ត៌មាននោះទៀតផងដែរ ដោយសារតែករណីនេះត្រូវបានដោះស្រាយរួចហើយ។ យុទ្ធសាស្ត្រនេះមានគោលបំណងបញ្ឈប់សាធារណជនកុំឱ្យមានការព្រួយបារម្ភអំពីជម្លោះការងារដែលកំពុងបន្តកើតមាន។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| ករណីនេះក្រសួងដោះស្រាយបងប្អូនរួចរាល់ហើយ | អត្ថបទបង្ហោះទី១ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |
| ក្រសួងបានចាត់វិធានការដោះស្រាយករណីនេះរួចរាល់ហើយ | អត្ថបទបង្ហោះទី១ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |
| សូមមេត្តាកុំផ្សព្វផ្សាយព័ត៌មានចាស់ ព្រោះករណីនេះបានដោះស្រាយរួចហើយ | អត្ថបទបង្ហោះទី១ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី២៖ ការជន់ជោរដោយសារផ្សព្វផ្សាយលេខទូរស័ព្ទទាន់ហេតុការណ៍រកការងារធ្វើ ១២៩៧*

នៅលើអត្ថបទបង្ហោះនានាដែលនិយាយអំពីបញ្ហាចំណាកស្រុក, កម្មវិធីអប់រំ, និងជំនួយស្បៀងអាហារ ផ្នែកមតិយោបល់ត្រូវបានបំពេញទៅដោយសារផ្សព្វផ្សាយអំពីលេខទូរស័ព្ទរកការងារធ្វើ ១២៩៧ របស់រាជរដ្ឋាភិបាល។ រឿងនេះបានកើតឡើងសូម្បីតែនៅលើអត្ថបទបង្ហោះស្តីពីជំនួយស្បៀងអាហារសម្រាប់គ្រួសារដែលផ្លាស់ទីលំនៅដោយសារជម្លោះ និងការអប់រំប្រឆាំងនឹងការជួញដូរមនុស្សសម្រាប់ស្ត្រី។ នៅលើអត្ថបទបង្ហោះស្តីពីការអប់រំប្រឆាំងនឹងការជួញដូរមនុស្សសម្រាប់ស្ត្រីមួយ ក្នុងចំណោមមតិយោបល់ទាំង ២៤ គឺសុទ្ធសឹងតែជាសារផ្សព្វផ្សាយលេខ ១២៩៧ ទាំងអស់ ហើយគ្មានមតិយោបល់ឆ្លើយតបពិតប្រាកដណាមួយទាល់តែសោះ។ ការជម្រុញសារស្វែងរកការងារធ្វើនៅលើអត្ថបទបង្ហោះប្រឆាំងនឹងការជួញដូរមនុស្ស គឺជាចំណុចដែលគួរឱ្យព្រួយបារម្ភខ្លាំង ព្រោះវាមានទម្រង់ស្រដៀងគ្នាទៅនឹងវិធីសាស្ត្រដែលប្រើប្រាស់ដោយក្រុមជនជួញដូរមនុស្ស និងក្រុមបោកប្រាស់រកការងារធ្វើ (job scammers)។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| បងប្អូនដែលត្រលប់មកពីក្រៅប្រទេសអាចស្វែងរកការងារតាមលេខ ១២៩៧ | អត្ថបទបង្ហោះទី១ របស់អង្គការខុមហ្វ្រែល ខែកុម្ភៈ ឆ្នាំ២០២៦ |
| ការងារមានច្រើនប្រភេទ សូមទាក់ទងទៅ ១២៩៧ | អត្ថបទបង្ហោះទី២ របស់អង្គការខុមហ្វ្រែល ខែកុម្ភៈ ឆ្នាំ២០២៦ |
| ខ្ញុំក៏ទើបបានការងារតាមក្រសួង ដោយហៅទៅលេខ ១២៩៧ | អត្ថបទបង្ហោះទី៦ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី៣៖ រឿងរ៉ាវផ្ទាល់ខ្លួនដែលមិនពិតប្រាកដ*

នៅលើអត្ថបទបង្ហោះនានាដែលនិយាយអំពីវិបត្តិចំណាកស្រុក និងបញ្ហាបំណុលរបស់កម្មករ គណនីដែលមានការចាត់តាំងជាប្រព័ន្ធបានបង្ហោះរឿងរ៉ាវជោគជ័យផ្ទាល់ខ្លួនដែលជាការប្រឌិតឡើង អំពីការស្វែងរកការងារធ្វើបានសម្រេចតាមរយៈលេខទូរស័ព្ទទាន់ហេតុការណ៍ ១២៩៧។ សារទាំងនេះត្រូវបានកំណត់អត្តសញ្ញាណថាមិនពិតប្រាកដ ដោយសារតែខ្លឹមសារនៃរឿងរ៉ាវដដែលៗនោះ បានលេចឡើងនៅលើអត្ថបទបង្ហោះខុសៗគ្នាជាច្រើន ដែលបង្ហោះដោយគណនីផ្សេងៗគ្នា និងនៅថ្ងៃខុសៗគ្នា ដែលវាមិនអាចទៅរួចឡើយសម្រាប់បទពិសោធន៍ផ្ទាល់ខ្លួនពិតប្រាកដរបស់មនុស្សម្នាក់ៗ។ ទម្រង់សារ (templates) ដដែលៗទាំងនេះ ត្រូវបានរកឃើញនៅលើអត្ថបទបង្ហោះខុសៗគ្នាយ៉ាងហោចណាស់ចំនួនប្រាំមួយរបស់អង្គការសង់ត្រាល់ (CENTRAL) ដែលគ្របដណ្តប់លើប្រធានបទ និងកាលបរិច្ឆេទខុសៗគ្នា។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| ខ្ញុំធ្លាប់ទាក់ទង ១២៩៧ បានការងារពិតៗ | អត្ថបទបង្ហោះទី៨ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |
| ខ្ញុំក៏ទើបបានការងារតាមក្រសួង ដោយហៅទៅលេខ ១២៩៧ ផងដែរ | អត្ថបទបង្ហោះទី៩ របស់អង្គការសង់ត្រាល់ ខែមីនា ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី៤៖ ការរិះគន់បែបការសិក្សាស្រាវជ្រាវដែលមិនពិតប្រាកដ*

នៅពេលដែលអង្គការសង់ត្រាល់ (CENTRAL) បានចេញផ្សាយរបាយការណ៍មួយស្តីពីពលករចំណាកស្រុកត្រឡប់មកវិញចំនួន ៩៥០.០០០ នាក់ មតិយោបល់ចំនួន ៨០ ភាគរយបានប្រើប្រាស់ពាក្យពេចន៍ដែលស្តាប់ទៅដូចជាការរិះគន់ផ្នែកស្រាវជ្រាវបែបការសិក្សា។ ប៉ុន្តែ មតិយោបល់ទាំងនេះមិនបានផ្តល់នូវអង្គហេតុពិតប្រាកដណាមួយឡើយ ពួកគេគ្រាន់តែព្យាយាមធ្វើឱ្យរបាយការណ៍នោះមើលទៅហាក់ដូចជាមិនគួរឱ្យទុកចិត្តប៉ុណ្ណោះ។ ឃ្លានីមួយៗត្រូវបានបង្ហោះដោយគណនីខុសៗគ្នាពីរបីទៅបួន។ គោលបំណងនៃយុទ្ធសាស្ត្រនេះ គឺធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវមើលទៅទន់ខ្សោយ និងបញ្ឆប់សាធារណជនកុំឱ្យយកចិត្តទុកដាក់ខ្លាំងលើការស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិល។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| ទិន្នន័យមិនគ្រប់គ្រាន់ ដើម្បីបង្ហាញស្ថានភាពពិត | អត្ថបទបង្ហោះទី២០ របស់អង្គការសង់ត្រាល់ ខែមីនា ឆ្នាំ២០២៦ |
| ទិន្នន័យមិនដឹងយកពីណាពិតប្រាកដទេ វាខុសនឹងជាក់ស្តែង | អត្ថបទបង្ហោះទី២០ របស់អង្គការសង់ត្រាល់ ខែមីនា ឆ្នាំ២០២៦ |
| ការស្រាវជ្រាវនេះមិនត្រឹមត្រូវបានភាពជាក់ស្តែងទេ | អត្ថបទបង្ហោះទី១៧ របស់អង្គការសង់ត្រាល់ ខែមីនា ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី៥៖ ការប្រើប្រាស់ឈ្មោះរបស់អង្គការ*

នៅលើអត្ថបទបង្ហោះមួយចំនួន គណនីយុទ្ធនាការបានប្រើប្រាស់ឈ្មោះជាភាសាខ្មែររបស់អង្គការសង់ត្រាល់នៅក្នុងមតិយោបល់របស់ពួកគេ ដើម្បីធ្វើឱ្យមើលទៅហាក់ដូចជាអង្គការសង់ត្រាល់ខ្លួនឯងកំពុងផ្សព្វផ្សាយលេខទូរស័ព្ទទាន់ហេតុការណ៍ ១២៩៧។ នេះគឺជាវិធីសាស្ត្រមួយក្នុងគោលបំណងបន្លំអ្នកអាន និងធ្វើឱ្យការផ្សព្វផ្សាយការងាររបស់រដ្ឋាភិបាលមើលទៅហាក់ដូចជាមានប្រភពមកពីអង្គការសង្គមស៊ីវិលដែលគួរឱ្យទុកចិត្តមួយ។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| សង់ត្រាល់អាចជួយផ្សព្វផ្សាយពី ១២៩៧ ដើម្បីអោយបងប្អូនទទួលបានការងារ | អត្ថបទបង្ហោះទី៥ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |
| សង់ត្រាល់ជួយផ្សព្វផ្សាយពី 1297 ដើម្បីចបងប្អូនទទួលបានការងារធ្វើ | អត្ថបទបង្ហោះទី១ របស់ប្រជាកាសែត ខែមីនា ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី៦៖ ការប្រើប្រាស់សុភាសិត «ផ្តល់ដងសន្ទូច ប្រសើរជាងផ្តល់ត្រី» ដើម្បីប្រឆាំងនឹងជំនួយ*

នៅពេលដែលអង្គការសង់ត្រាល់ (CENTRAL) បានផ្តល់ស្បៀងអាហារដល់គ្រួសារដែលបាត់បង់ផ្ទះសម្បែងនៅក្នុងជម្លោះព្រំដែន គណនីមួយចំនួនបានប្រើប្រាស់ពាក្យស្លោក «ផ្តល់ដងសន្ទូច ប្រសើរជាងផ្តល់ត្រី» (teach a man to fish) ដើម្បីវែកញែកថា ការផ្តល់ជំនួយស្បៀងអាហារគឺមិនមានប្រយោជន៍នោះទេ ហើយអង្គការសង់ត្រាល់គួរតែជម្រុញការរកការងារធ្វើជំនួសវិញ។ ការធ្វើបែបនេះ បានបង្វែរទិសដៅអត្ថបទបង្ហោះអំពីជំនួយមនុស្សធម៌ ឱ្យទៅជាសារផ្សព្វផ្សាយការងាររបស់រដ្ឋាភិបាលទៅវិញ និងបានបដិសេធចោលនូវតម្រូវការចាំបាច់របស់គ្រួសារដែលកំពុងផ្លាស់ទីលំនៅទាំងនោះ។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| យើងអាចឲ្យត្រីទៅអ្នកដែលកំពុងតែស្រេកឃ្លាន គឺល្អ ប៉ុន្តែបើផ្តល់ត្រីបន្ត គឺមិនអាចជោគជ័យ | អត្ថបទបង្ហោះទី៥ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |
| យើងអាចឲ្យត្រីទៅអ្នកដែលកំពុងស្រេកឃ្លាន គឺល្អ ប៉ុន្តែបើផ្តល់ត្រីបន្តទៀត គឺពិបាកក្លាយជាអ្នកស្ទុះ | អត្ថបទបង្ហោះទី៥ របស់អង្គការសង់ត្រាល់ ខែកុម្ភៈ ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី៧៖ ការលាបពណ៌ប្រភពព័ត៌មានថាជា «វិទ្យុប្រឆាំង»*

អង្គការសង់ត្រាល់ (CENTRAL) តែងតែចែករំលែកជាទៀងទាត់នូវអត្ថបទបង្ហោះពីវិទ្យុអាស៊ីសេរី (RFA) ដែលជាស្ថាប័នផ្សព្វផ្សាយអន្តរជាតិហិរញ្ញប្បទានដោយសហរដ្ឋអាមេរិក និងជាស្ថានីយវិទ្យុឯករាជ្យមួយដែលផ្សាយជាភាសាខ្មែរ។ គណនីយុទ្ធនាការមួយចំនួនបានឆ្លើយតបទៅវិញដោយហៅវិទ្យុអាស៊ីសេរី (RFA) ថាជា «ស្ថានីយវិទ្យុប្រឆាំង» ដែលមិនអើពើចំពោះកម្មករខ្មែរ។ យុទ្ធសាស្ត្រនេះព្យាយាមបង្ខូចកេរ្តិ៍ឈ្មោះប្រភពព័ត៌មានដែលអង្គការសង់ត្រាល់ប្រើប្រាស់ ដោយការលាបពណ៌ស្ថាប័នទាំងនោះថាមាននិន្នាការនយោបាយប្រឆាំងនឹងរដ្ឋាភិបាល។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| ពលករខ្មែរវិលត្រឡប់មកដើម្បីរកការងារក្នុងស្រុក តែវិទ្យុប្រឆាំងសុទ្ធតែមើលរំលង | អត្ថបទបង្ហោះទី២១ របស់អង្គការសង់ត្រាល់ ខែមីនា ឆ្នាំ២០២៦ |

### *យុទ្ធសាស្ត្រទី៨៖ ការចោទសួរលើរបាយការណ៍អំពីមរណភាព*

នៅពេលដែលអង្គការសង់ត្រាល់ (CENTRAL) បានរាយការណ៍អំពីពលករម្នាក់ដែលបានបាត់បង់ជីវិតនៅក្នុងគ្រោះថ្នាក់ការងារនៅរោងចក្រមួយក្នុងប្រទេសថៃ គណនីខុសៗគ្នាចំនួនបួនបានបង្ហោះនូវសំណួរដូចគ្នាបេះបិទនៅក្នុងមតិយោបល់របស់ពួកគេ ដោយសាកសួរថាតើករណីនោះជារឿងពិតប្រាកដដែរឬទេ។ យុទ្ធសាស្ត្រនៃការរួមគ្នាចោទសួរលើករណីមរណភាពដែលមានឯកសារភស្តុតាងច្បាស់លាស់បែបនេះ គឺត្រូវបានរៀបចំឡើងដើម្បីបញ្ឈប់មនុស្សកុំឱ្យយកចិត្តទុកដាក់លើករណីនេះ និងដើម្បីកាត់បន្ថយសម្ពាធទៅលើនិយោជក ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច។

| មតិយោបល់ដើម ជាភាសាខ្មែរ | ប្រភពនៃអត្ថបទបង្ហោះ |
|---|---|
| តើករណីនេះពិតឬអត់ សូមផ្តល់ព័ត៌មានផង | អត្ថបទបង្ហោះទី២២ របស់អង្គការសង់ត្រាល់ (ករណីមរណភាពពលករ, ប្រទេសថៃ) ខែមេសា ឆ្នាំ២០២៦ |
| គ្រោះថ្នាក់នៅស្រុកគេ ចឹងពិបាក់ដែរ មិនមែននៅខ្មែរ | អត្ថបទបង្ហោះទី២២ របស់អង្គការសង់ត្រាល់ (ករណីមរណភាពពលករ, ប្រទេសថៃ) ខែមេសា ឆ្នាំ២០២៦ |

### *អត្រាសារដែលមិនពិតប្រាកដ ផ្អែកតាមប្រភេទនៃអត្ថបទបង្ហោះ*

| ប្រភេទអត្ថបទបង្ហោះ | អត្រាសារដែលមិនពិតប្រាកដ | អត្រាសារពិតប្រាកដ | យុទ្ធសាស្ត្រចម្បង |
|---|---|---|---|
| របាយការណ៍អំពីការតវ៉ានៅរោងចក្រ | ៩៤% | ៦% | «ក្រសួងបានដោះស្រាយរួចរាល់» |
| ការអប់រំអំពីការប្រឆាំងការជួញដូរមនុស្ស | ១០០% | ០% | ការសម្រុកបង្ហោះសារលេខ ១២៩៧ |
| ជំនួយស្បៀងអាហារមនុស្សធម៌ | ៨០% ទៅ ៩៥% | ៥% ទៅ ២០% | លេខ ១២៩៧ និងសុភសិត «ផ្តល់ដងសន្ទូចប្រសើរជាងផ្តល់ត្រី» |
| របាយការណ៍ស្រាវជ្រាវ | ៨០% | ២០% | ការរិះគន់ផ្អែកស្រាវជ្រាវដែលមិនពិតប្រាកដ |

| | | | |
|---|---|---|---|
| មរណភាពពលករនៅប្រទេសថៃ | ៨៥% | ១៥% | ការចោទសួរលើករណីមរណភាព |
| ព័ត៌មានទាន់ហេតុការណ៍ខ្លីៗស្ដីពីកូដកម្ម | ១៣% | ៨៧% | ស្ទើរតែគ្មានសកម្មភាពយុទ្ធនាការ |
| វេទិការួមគ្នាជាមួយទូរទស្សន៍អាស៊ីសេរី | ៩៨% | ២% | ការសម្រុកបង្ហោះទិន្នន័យស្ថិតិ និងការវាយប្រហារលើវិទ្យុ TFA |

*តារាងទី៦៖ អង្គការសង់ក្រាល់៖ អត្រាមតិយោបល់ដែលមិនពិតប្រាកដ ផ្អែកតាមប្រភេទនៃអត្ថបទបង្ហោះ*

## ៣.៤ អង្គការកំហ្វ្រែល — គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវដោយយុត្តិធម៌នៅកម្ពុជា

### *ទិដ្ឋភាពទូទៅ*

អត្ថបទបង្ហោះចំនួនបួនរបស់អង្គការកំហ្វ្រែល (Comfrel) ត្រូវបានយកមកធ្វើការវិភាគ ដោយមានមតិយោបល់សរុបចំនួន ៣៧២។ អង្គការកំហ្វ្រែលបានចែករំលែកនូវរឿងរ៉ាវព័ត៌មានពីប្រភពវិទ្យុបារាំងអន្តរជាតិ (RFI) ជាភាសាខ្មែរ, សារព័ត៌មាន Kiripost ជាភាសាខ្មែរ និងសារព័ត៌មាន CamboJa News ដែលទាក់ទងនឹងពលករចំណាកស្រុក និងការធ្វើកូដកម្មនៅតាមរោងចក្រ។

| **អត្ថបទបង្ហោះ** | **មតិយោបល់** | **សញ្ញាណរកឃើញ** | **ខ្ពស់** | **មធ្យម** | **ទាប** | **មិនមានពាក្យសម្ដីស្អប់ខ្ពើម** |
|---|---|---|---|---|---|---|
| អត្ថបទបង្ហោះទី១៖ ពលករត្រឡប់មកពីប្រទេសថៃប្រឈមនឹងបញ្ហាបំណុល (វិទ្យុ RFI ជាភាសាខ្មែរ) | ១២១ | ០ | ០ | ០ | ០ | ១២១ |
| អត្ថបទបង្ហោះទី២៖ ពលករជិត ១០ម៉ឺននាក់ជាប់គាំងនៅក្នុងប្រទេសថៃ (សារព័ត៌មាន Kiripost ជាភាសាខ្មែរ) | ១៦០ | ១ | ០ | ០ | ១ | ១៥៩ |
| អត្ថបទបង្ហោះទី៣៖ កម្មករកាត់ដេរធ្វើកូដកម្ម (សារព័ត៌មាន CamboJa News) | ៤១ | ០ | ០ | ០ | ០ | ៤១ |

| | | | | | | |
|---|---|---|---|---|---|---|
| អត្ថបទបង្ហោះទី៤៖ ពលករ ៨ម៉ឺននាក់មានទិដ្ឋាការហួសសុពលភាព (វិទ្យុ RFI ជាភាសាខ្មែរ) | ៥០ | ០ | ០ | ០ | ០ | ៥០ |
| **សរុប** | **៣៧២** | ១ | **០** | **០** | **១** | **៣៧១** |

*តារាងទី៧ក៖ Comfrel, ការវិភាគខ្លឹមសារស្អប់ខ្ពើមតាមរយៈអត្ថបទបង្ហោះ*

| **អត្ថបទបង្ហោះ** | **មតិយោបល់** | **សញ្ញាណរកឃើញ** | **លំនាំភាពមិនពិតប្រាកដ** | **ភាពពិតប្រាកដ** | **អត្រាភាពមិនពិតប្រាកដ** |
|---|---|---|---|---|---|
| អត្ថបទបង្ហោះទី១៖ ពលករត្រឡប់មកពីប្រទេសថៃប្រឈមនឹងបញ្ហាបំណុល (វិទ្យុ RFI ជាភាសាខ្មែរ) | ១២១ | ៣០ | ៩៧ | ២៤ | ៨០% |
| អត្ថបទបង្ហោះទី២៖ ពលករជិត ១០ម៉ឺននាក់ជាប់គាំងនៅក្នុងប្រទេសថៃ (សារព័ត៌មាន Kiripost ជាភាសាខ្មែរ) | ១៦០ | ១០៣ | ១២៥ | ៣៥ | ៧៨% |
| អត្ថបទបង្ហោះទី៣៖ កម្មករកាត់ដេរធ្វើកូដកម្ម (សារព័ត៌មាន CamboJa News) | ៤១ | ២១ | ៣៦ | ៥ | ៨៨% |
| អត្ថបទបង្ហោះទី៤៖ ពលករ ៨ម៉ឺននាក់មានទិដ្ឋាការហួសសុពលភាព (វិទ្យុ RFI ជាភាសាខ្មែរ) | ៥០ | ៤៤ | ៣៩ | ១១ | ៧៨% |
| **សរុប** | **៣៧២** | **១៨៥** | **2៩៧** | **៧៥** | **៨០%** |

*តារាងទី៧ខ៖ Comfrel, ការវិភាគយុទ្ធនាការមិនប្រក្រតីតាមរយៈអត្ថបទបង្ហោះ*

## ឧទាហរណ៍នៃមតិយោបល់

| មតិយោបល់ដើម |
|---|
| ការងារនៅក្នុងប្រទេសមានឱកាសអភិវឌ្ឍជំនាញផ្ទាល់ខ្លួន |
| សូមមេត្តាជួយផ្សព្វផ្សាយឱកាសការងារទៅដល់បងប្អូនដែលមិនទាន់មានការងារធ្វើផង |
| ការងារនៅក្នុងប្រទេសយើងមានច្រើនណាស់ សូមបងប្អូនកុំអស់សង្ឃឹម |
| សូមផ្សព្វផ្សាយឱកាសការងារជំនួសការផ្សាយពាក្យចចាមអារ៉ាម |
| ការងារមានច្រើនប្រភេទ សូមទាក់ទងទៅ ១២៩៧ |
| សូមជួយអោយបងប្អូនដែលអត់ការងារទទួលបានព័ត៌មាននេះ |
| ក្រសួងបានដោះស្រាយករណីនេះរួចរាល់ហើយ |
| ក្រសួងគេដោះស្រាយរួចរាល់ហើយ |
| ក្រសួងដោះស្រាយជូនរួចរាល់ហើយ សូមមេត្តាជួយយោគយល់ |

### *លទ្ធផលរកឃើញសំខាន់ៗ*

អង្គការកំហ្វ្រែល (Comfrel) មានចំនួនមតិយោបល់ជាន់ៗគ្នា (Duplicate comments) ខ្ពស់ជាងគេបំផុតនៅក្នុងការសិក្សានេះ។ ក្នុងចំណោមមតិយោបល់សរុបចំនួន ៣៧២ មានមតិយោបល់ចំនួន ២៣១ (៦២ ភាគរយ) គឺជាសារដដែលៗដែលត្រូវបានបង្ហោះដោយគណនីខុសៗគ្នា។ នៅពេលធ្វើការប្រៀបធៀបរវាងអត្ថបទបង្ហោះទី១ និងទី៤ ដែលសុទ្ធសឹងតែដកស្រង់ចេញពីវិទ្យុ RFI ជាភាសាខ្មែរ និងនិយាយអំពីពលករចំណាកស្រុកដូចគ្នា គេសង្កេតឃើញមានមតិយោបល់ចំនួន ៩០ បានប្រើប្រាស់ខ្លឹមសារអក្សរដូចគ្នាបេះបិទនៅលើអត្ថបទបង្ហោះទាំងពីរនេះ។ គណនីដដែលៗទាំងនោះបានបង្ហោះសារដូចគ្នាបេះបិទនៅលើអត្ថបទបង្ហោះពីរខុសគ្នាដែលត្រូវបានផ្សព្វផ្សាយនៅក្នុងសប្តាហ៍ខុសគ្នា។ នេះគឺជាភស្តុតាងដ៏រឹងមាំមួយដែលបង្ហាញពីយុទ្ធនាការដែលមានការរៀបចំទុកជាមុន ដើម្បីវាយប្រហារលើការផ្សាយព័ត៌មានរបស់វិទ្យុ RFI ជាភាសាខ្មែរ អំពីវិបត្តិពលករចំណាកស្រុក។

ចំពោះអត្ថបទបង្ហោះទី៣ ស្តីពីកូដកម្មរបស់កម្មករកាត់ដេរវិញ ត្រូវបានសម្រុកបង្ហោះបំផ្លាញដោយសារដែលមានខ្លឹមសារថា «ក្រសួងបានដោះស្រាយរឿងនេះរួចរាល់ហើយ»។ នេះគឺជាយុទ្ធសាស្ត្រដូចគ្នាបេះបិទទៅនឹងយុទ្ធសាស្ត្រដែលត្រូវបានប្រើប្រាស់នៅលើអត្ថបទបង្ហោះពាក់ព័ន្ធនឹងបញ្ហាការងាររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) និងអង្គការសង់ត្រាល់ (CENTRAL) ផងដែរ។ វាបានបង្ហាញឱ្យឃើញថា មានក្រុមតែមួយកំពុងកំណត់គោលដៅវាយប្រហារទៅលើអង្គការសង្គមស៊ីវិលខុសៗគ្នាជាច្រើនក្នុងពេលតែមួយ។

## ៣.៥ អង្គការលីកាដូ — សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (LICADHO)

### *ទិដ្ឋភាពទូទៅ*

អត្ថបទបង្ហោះចំនួនបួនរបស់អង្គការលីកាដូ ត្រូវបានយកមកធ្វើការវិភាគ ដោយមានមតិយោបល់សរុបចំនួន ២,៣៨៤។ នេះគឺជាចំនួនមតិយោបល់ដ៏ច្រើនបំផុតក្នុងចំណោមអង្គការទាំងអស់នៅក្នុងការសិក្សាស្រាវជ្រាវនេះ។

អត្ថបទបង្ហោះទាំងនោះរួមមានៈ

- អត្ថបទបង្ហោះទី១ (មតិយោបល់ចំនួន ៥២៦)៖ ស្តីពីការកាត់ទោសដាក់ពន្ធនាគារជាលើកទីបីលើសកម្មជន លោក ភុន យុត (Phun Yut) ចំពោះការបញ្ចេញមតិយោបល់នៅលើបណ្តាញសង្គម។
- អត្ថបទបង្ហោះទី២ (មតិយោបល់ចំនួន ១៨៤)៖ ស្តីពីខួប ១៤ឆ្នាំ នៃការលបឃាតកម្មលើសកម្មជនការពារព្រៃឈើ លោក ឈុត វុទ្ធី (Chut Wutty) ដោយគ្មានការស៊ើបអង្កេតស្វែងរកការពិត។
- អត្ថបទបង្ហោះទី៣ (មតិយោបល់ចំនួន ៨៥១)៖ ស្តីពីការចាប់ខ្លួននាយករងសាលាម្នាក់ និងកម្មកររោងចក្រម្នាក់ ចំពោះការបង្ហោះសារនៅលើហ្វេសប៊ុកពាក់ព័ន្ធនឹងបញ្ហាព្រំដែន។
- អត្ថបទបង្ហោះទី៤ (មតិយោបល់ចំនួន ៨២៣)៖ ស្តីពីការផ្តន្ទាទោសលើកម្មកររោងចក្រ លោក ហុល មុនីសាម៉ន (Hul Monisamon) ចំពោះការបង្ហោះសារពាក់ព័ន្ធនឹងព្រំដែនកម្ពុជា និងថៃ។

| **អត្ថបទបង្ហោះ** | **មតិយោបល់** | **សញ្ញាណរកឃើញ** | **ខ្ពស់** | **មធ្យម** | **ទាប** | **មិនមានពាក្យសម្តីស្អប់ខ្ពើម** |
|---|---|---|---|---|---|---|
| អត្ថបទបង្ហោះទី១៖ ការកាត់ទោសដាក់ពន្ធនាគារជាលើកទី ៣ លើលោក ភុន យុត | ៥២៦ | ២៨ | ២ | ២១ | ៥ | ៤៩៨ |
| អត្ថបទបង្ហោះទី២៖ ខួប ១៤ឆ្នាំ នៃការលបឃាតកម្មលើលោក ឈុត វុទ្ធី | ១៨៤ | ៦ | ២ | ៤ | ០ | ១៧៨ |
| អត្ថបទបង្ហោះទី៣៖ ការចាប់ខ្លួននាយករងសាលា និងកម្មកររោងចក្រ | ៨៥១ | ៣០ | ០ | ២៦ | ៤ | ៨២១ |

| | | | | | | |
|---|---|---|---|---|---|---|
| អត្ថបទបង្ហោះទី៤៖ ការផ្តន្ទាទោសលើលោក ហុល មុនីសាម៉ន | ៨២៣ | ២១ | ១ | ១៨ | ២ | ៨០២ |
| **TOTAL** | **២,៣៨៤** | **៨៥** | **៥** | **៦៩** | **១១** | **២,២៩៩** |

*តារាងទី៨ក៖ Licadho, ការវិភាគខ្លឹមសារស្អប់ខ្ពើមតាមរយៈអត្ថបទបង្ហោះ*

| **អត្ថបទបង្ហោះ** | **មតិយោបល់** | **សញ្ញាណរកឃើញ** | **លំនាំភាពមិនពិតប្រាកដ** | **ភាពពិតប្រាកដ** | **អត្រាភាពមិនពិតប្រាកដ** |
|---|---|---|---|---|---|
| អត្ថបទបង្ហោះទី១៖ ការកាត់ទោសដាក់ពន្ធនាគារជាលើកទី៣ លើលោក ភុន យុត | ៥២៦ | ១៨ | ៤៦ | ៤៨០ | ៩% |
| អត្ថបទបង្ហោះទី២៖ ខួប ១៤ ឆ្នាំ នៃការលបឃាតកម្មលើលោក ឈុត វុទ្ធី | ១៨៤ | ១១ | ៩ | ១៧៥ | ៥% |
| អត្ថបទបង្ហោះទី៣៖ ការចាប់ខ្លួននាយករងសាលា និងកម្មកររោងចក្រ | ៨៥១ | ១៥ | ១២៧ | ៧២៤ | ១៥% |
| អត្ថបទបង្ហោះទី៤៖ ការផ្តន្ទាទោសលើលោក ហុល មុនីសាម៉ន | ៨២៣ | ៣០ | ១០៨ | ៧១៥ | ១៣% |
| **សរុប** | **២,៣៨៤** | **៧១** | **២៩០** | **២,០៩៤** | **១២%** |

*តារាងទី៨ខ៖ Licadho, ការវិភាគយុទ្ធនាការមិនប្រក្រតីតាមរយៈអត្ថបទបង្ហោះ*

## ឧទាហរណ៍នៃមតិយោបល់

| **មតិយោបល់ដើម** |
|---|
| បើច្បាប់តិរច្ឆានដូចពួកឯងអញ្ចឹងហើយចាប់មនុស្សបាញ់ចោលឱ្យអស់កម្មង់ទៅអើយ |
| បើពិបាកពេកចឹងសម្លាប់ចោលអោយអស់ទៅទុកតែមន្ត្រីៗសុទ្ធទៅកុំទុកប្រជាជននាំពិបាកដឹកនាំ |
| អាណាឲ្យបាញ់ ដឹងអស់ហើយតើអី ? អាណាឈឺឆ្អាលរឿងជាតិគឺងាប់ឆាប់ នៅល្ងង់ម៉េះ |
| ស្តាយធុនធានត្រូវអាឆ្កែយួនវាបាញ់សម្លាប់លោក |
| ត្រឹមតែជាស្រីទន់ខ្សោយម្នាក់ក៏មិនលើកលែង ឆ្ងល់ទៅវត្តធ្វើអីរាល់ថ្ងៃនាក់ចាប់គេនឹង ជឿបុណ្យបាបដែរតែធ្វើបាប់គេ |

| |
|---|
| គ្រាន់តែមិនចេញមតិមានកំហុសដាក់ទោសជាប់ពាន់ធនាគារ។រឹងអ្នកប្លន់ដីរាស្ត្រអ្នកយកដីរាស្ត្រ។អ្នកបោកប្រាស់ប្រជាពលរដ្ឋ។អត់មានឃើញអាឆ្កែទេចាប់ដាក់គុកអីមួយ។ខ្លួនឯងមានកំហុសជាស្ដីថាបន្តិចបន្តចមិនកែកំហុស។ ខ្លួនឯងខុសគេនិយាយមិនបាន។អីក៏អន់ម្ល៉េះ |
| មន្ត្រីស្រុកខ្មែរ១ចំនួនម្នាក់ៗមិនស្មើនឹងឆ្កែផង |
| អាឆ្កែណាចាប់គាត់ដាក់គុកអោយហែងបែកបាក់បងប្អូនញាតិសន្តាន |
| និយាយមិនបានទេ ស្រុកខ្មែរឡូវ ដឹងធ្វើនាក់ចេះដឹងអាចម៍ឆ្កែអីទេ បើនិយាយចាប់ៗ |
| សម្លាប់វាចោលទៅអាជនពិការ |

## *លទ្ធផលរកឃើញសំខាន់ៗ*

អត្ថបទបង្ហោះរបស់អង្គការលីកាដូ (LICADHO) ទទួលបានការឆ្លើយតបពិតប្រាកដពីមហាជនច្រើនជាងគេបំផុត ហើយក៏ជាអង្គការដែលទទួលបានមតិយោបល់ដែលត្រូវបានដៅចំណាំ (Flagged comments) ច្រើនជាងគេបំផុតនៅក្នុងចំណោមអង្គការទាំងអស់ផងដែរ។ អត្ថបទបង្ហោះទី៣ និងទី៤ ដែលនិយាយអំពីប្រជាពលរដ្ឋសាមញ្ញត្រូវបានចាប់ខ្លួនដោយសារតែការបង្ហោះសារលើហ្វេសប៊ុកពាក់ព័ន្ធនឹងបញ្ហាព្រំដែន បានបង្កឱ្យមានការខឹងសម្បារយ៉ាងខ្លាំងពីសំណាក់មហាជនពិតប្រាកដ។ មនុស្សជាច្រើនបានសម្ដែងនូវការខកចិត្ត និងភាពអស់សង្ឃឹម។ អត្ថបទបង្ហោះទី៣ និងទី៤ នេះ ក៏បានចែករំលែកមតិយោបល់ដូចគ្នាចំនួន ១៦៧ សារ នៅលើអត្ថបទបង្ហោះទាំងពីរពីគណនីដដែលៗ ដែលនេះបង្ហាញថាមានគណនីដដែលៗកំពុងបង្ហោះសារដែលបង្វែរអារម្មណ៍ដូចគ្នានៅលើអត្ថបទបង្ហោះទាំងពីរ ដែលវាឆ្លុះបញ្ចាំងពីការគ្រប់គ្រងនិងរៀបចំទុកជាមុនទៅលើប្រតិកម្មរបស់មហាជន។

មតិយោបល់ទាំងនោះបានបង្ហាញពីមនោសញ្ចេតនាជាតិនិយមយ៉ាងខ្លាំងក្លាជុំវិញជម្លោះព្រំដែនកម្ពុជា និងថៃ។ ប្រជាពលរដ្ឋបានសម្ដែងការខឹងសម្បារដែលពលរដ្ឋត្រូវបានចាប់ខ្លួនដោយសារតែការនិយាយអំពីបញ្ហាព្រំដែនក្នុងពេលដែលអ្នកបង្កគ្រោះថ្នាក់ដល់ប្រជាជនកម្ពុជាបែរជាមិនប្រឈមមុខនឹងផលវិបាកណាមួយសោះ។ មនោសញ្ចេតនានេះហាក់ដូចជាកើតចេញពីចិត្តពិតប្រាកដ និងឆ្លុះបញ្ចាំងពីការខកចិត្តពិតប្រាកដរបស់មហាជន មិនមែនជាយុទ្ធនាការដែលរៀបចំឡើងដោយមិនពិតប្រាកដនោះឡើយ។

អត្ថបទបង្ហោះមួយស្ដីពីពលករខ្មែរម្នាក់បានស្លាប់នៅក្នុងគ្រោះថ្នាក់ការងារនៅរោងចក្រក្នុងប្រទេសកម្ពុជា មិនទទួលបានការឆ្លើយតបជាលក្ខណៈយុទ្ធនាការមិនពិតប្រាកដទាល់តែសោះ ពោលគឺមានតែការចូលរួមរំលែកទុក្ខពិតប្រាកដពីមហាជនប៉ុណ្ណោះ។ ប៉ុន្តែ អត្ថបទបង្ហោះទី១ ស្ដីពីពលករខ្មែរម្នាក់បានស្លាប់ក្នុងករណីបាក់ដំបូលរោងចក្រនៅប្រទេសថៃ (ករណីមន្ទីរពេទ្យសិរិរាជ - Siriraj Hospital case) វិញ ទទួលបានការឆ្លើយតបមិនពិតប្រាកដរហូតដល់ ៨៥ ភាគរយ។ នេះបង្ហាញឱ្យឃើញថា យុទ្ធនាការនេះបានកំណត់គោលដៅជាពិសេសទៅលើអត្ថបទបង្ហោះណាដែលអាចបង្កើតឱ្យមានសម្ពាធពីមហាជនទៅលើនិយោជកថៃ។

## ៣.៦ ប្រជាកាសែត (ProcheaKaset)

### *ទិដ្ឋភាពទូទៅ*

អត្ថបទបង្ហោះមួយរបស់ប្រជាកាសែត (ProcheaKaset) ត្រូវបានយកមកធ្វើការវិភាគ។ អត្ថបទនោះគឺជាវីដេអូរបស់កម្មការិនីរោងចក្រម្នាក់គឺកញ្ញា វ៉ាន់ ថានា ដែលបានឡើងថ្លែងនៅក្នុងព្រឹត្តិការណ៍ទិវាពលកម្មអន្តរជាតិ (ទិវាពលកម្ម១ឧសភា) អំពីបញ្ហាប្រឈមនៃការទទួលបានប្រាក់តាមបុង (Piece-rate pay)។ ប្រជាកាសែតបានបង្កើតទំព័រហ្វេសប៊ុក (Facebook) របស់ខ្លួននៅក្នុងខែមេសា ឆ្នាំ២០២៥។ ទោះបីជាវាជាស្ថាប័នថ្មីមួយក៏ដោយ ក៏អត្ថបទបង្ហោះមួយនេះទទួលបានមតិយោបល់រហូតដល់ទៅ ៩០៥ សារ និងជាអត្ថបទបង្ហោះដែលទទួលបានមតិយោបល់ច្រើនជាងគេលំដាប់ទីពីរ ក្នុងចំណោមអត្ថបទបង្ហោះសរុបចំនួន ៣០១ របស់ប្រជាកាសែត ដែលបានផ្សព្វផ្សាយនៅចន្លោះខែកុម្ភៈ ដល់ខែមេស ឆ្នាំ២០២៦។

| អត្ថបទបង្ហោះ | មតិយោបល់ | សញ្ញាណរកឃើញ | ខ្ពស់ | មធ្យម | ទាប | មិនមានពាក្យសម្តីស្អប់ខ្ពើម |
|---|---|---|---|---|---|---|
| អត្ថបទបង្ហោះ៖ កម្មកររោងចក្រដែលទទួលបានប្រាក់ឈ្នួលតាមបុង | ៩០៥ | ០ | ០ | ០ | ០ | ៩០៥ |

*តារាងទី៩ក៖ ProcheaKaset, ការវិភាគខ្លឹមសារស្អប់ខ្ពើមតាមរយៈអត្ថបទបង្ហោះ*

| អត្ថបទបង្ហោះ | មតិយោបល់ | សញ្ញាណរកឃើញ | លំនាំភាពមិនពិតប្រាកដ | ភាពពិតប្រាកដ | អត្រាភាពមិនពិតប្រាកដ |
|---|---|---|---|---|---|
| អត្ថបទបង្ហោះ៖ កម្មកររោងចក្រដែលទទួលបានប្រាក់ឈ្នួលតាមបុង | ៩០៥ | ២ | ៦ | ៨៩៩ | ១% |

*តារាងទី៨ខ៖ ProcheaKaset, ការវិភាគយុទ្ធនាការមិនប្រក្រតីតាមរយៈអត្ថបទបង្ហោះ*

### *លទ្ធផលរកឃើញសំខាន់ៗ*

មតិយោបល់ភាគច្រើនគឺបង្ហាញការគាំទ្រដល់កម្មការិនីរោងចក្រ។ ឃ្លាខ្លីៗជាច្រើនបានលេចឡើងជាច្រើនលើកច្រើនសារឆ្លងកាត់គណនីខុសៗគ្នា ដូចជាឃ្លាថា “និយាយត្រូវបង” និងឃ្លាថា “និយាយត្រូវណាស់ចែ”។ ទោះបីជាឃ្លាទាំងនេះត្រូវបានប្រើប្រាស់ដដែលៗក៏ដោយ ក៏ការសិក្សាស្រាវជ្រាវនេះមិនចាត់ថ្នាក់ពួកវាថាជាសារមិនពិតប្រាកដ ដោយផ្អែកលើតែខ្លឹមសារតែមួយមុខនោះឡើយ។ ការចាត់ថ្នាក់នៅក្នុងការសិក្សានេះ គឺផ្អែកលើការវិភាគទៅលើឥរិយាបថរបស់គណនី (Account behavior) មិនមែនផ្អែកលើការដែលមតិយោបល់នោះបង្ហាញការយល់ស្រប ឬមិនយល់ស្របជាមួយកម្មការិនីរូបនោះទេ។

ឃ្លាបង្ហាញការគាំទ្រដែលប្រើប្រាស់ដដែលៗទាំងនេះ ត្រូវបានចាត់ទុកថាជាមតិយោបល់ពិតប្រាកដ ដោយសារមូលហេតុបីយ៉ាង។

ទីមួយ គណនីទាំងឡាយដែលបានបង្ហោះសារទាំងនោះ ត្រូវបានយកទៅផ្ទៀងផ្ទាត់យ៉ាងម៉ត់ចត់ជាមួយលក្ខវិនិច្ឆ័យចំណាំ (Flagging criteria) ដែលប្រើប្រាស់នៅក្នុងការសិក្សានេះ រួមមាន គណនីដែលទើបតែត្រូវបានបង្កើតថ្មីៗ, គណនីដែលអសកម្ម (មិនមានសកម្មភាព) លើសពីបួនសប្តាហ៍ និងគណនីទាំងឡាយដែលត្រូវបានបង្កើតឡើងនៅក្នុងខែតែមួយជាមួយគណនីដទៃទៀតនៅក្នុងបណ្តុំតែមួយ។ លទ្ធផលគឺមិនមានគណនីណាមួយដែលបានបង្ហោះឃ្លាគាំទ្រទាំងនេះ ចូលក្នុងលក្ខវិនិច្ឆ័យចាប់ពីពីរឡើងទៅនោះឡើយ ដែលនេះមានន័យថា ពួកគេមិនបានបង្ហាញសញ្ញាឥរិយាបថសង្ស័យនៃគណនីមិនពិតប្រាកដនោះទេ។

ទីពីរ ឃ្លាបង្ហាញការយល់ស្របខ្លីៗ ដូចជាឃ្លាថា "និយាយត្រូវបង" ឬ "មែនហើយបង" គឺទម្រង់លំនាំធម្មតានៅលើបណ្តាញសង្គម ជាពិសេសនៅពេលដែលមានមនុស្សជាច្រើនបានទស្សនាវីដេអូដែលមានភាពរំជើបរំជួលចិត្តដូចគ្នាក្នុងពេលតែមួយ។ ចំណុចនេះមានភាពខុសប្លែកស្រឡះពីទម្រង់សារគំរូដូចគ្នាបេះបិទពាក្យមួយម៉ាត់ៗ ដែលប្រើប្រាស់ដោយយុទ្ធនាការមិនពិតប្រាកដ ដែលសារទាំងនោះត្រូវបានបង្ហោះដោយគណនីដែលត្រូវបានកត់yចំណាំ (Flagged accounts) ឆ្លងកាត់ទំព័ររបស់អង្គការជាច្រើន។

ទីបី មតិយោបល់គាំទ្រជាច្រើនបានបញ្ជាក់បញ្ចូលនូវព័ត៌មានលម្អិតផ្ទាល់ខ្លួនអំពីកន្លែងធ្វើការ, ប្រាក់ខែ ឬបញ្ហាសុខភាពផ្ទាល់ខ្លួនរបស់អ្នកបញ្ចេញមតិ។ ព័ត៌មានលម្អិតផ្ទាល់ខ្លួនទាំងនេះ គឺជាសញ្ញាសម្គាល់ដ៏រឹងមាំនៃការចូលរួមដោយពិតប្រាកដ (Genuine engagement) ហើយមិនមែនជាលទ្ធផលដែលកើតចេញពីសកម្មភាពមិនពិតប្រាកដដែលសហការគ្នាជាប្រព័ន្ធនោះឡើយ។

មានមតិយោបល់ចំនួនតែពីរប៉ុណ្ណោះដែលបានមកពីគណនីមិនពិតប្រាកដ។ គណនីឈ្មោះ Va Vy បានផ្សព្វផ្សាយអំពីឱកាសការងារក្នុងស្រុក ដែលវាស្របគ្នាទៅនឹងយុទ្ធនាការផ្សព្វផ្សាយប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍រកការងារធ្វើរបស់ក្រសួង ១២៩៧ ដូចដែលបានឃើញនៅលើទំព័ររបស់អង្គការដទៃទៀតដែរ។ ចំណែកឯគណនីឈ្មោះ Pov Hour វិញ បានចេញមុខការពារការបើកប្រាក់គិតតាមបុងថាជាប្រព័ន្ធជម្រុញផលិតភាពការងារ ដែលនេះជាសារតបតដើម្បីបដិសេធទៅនឹងអ្វីដែលកម្មការិនីបានលើកឡើងនៅក្នុងវីដេអូ។ គណនីទាំងពីរនេះមិនមែនជាគណនីពិតប្រាកដនោះឡើយ។ គណនី Va Vy ស្ថិតនៅក្នុងបណ្តុំគណនីបង្កើតឡើងកាលពីខែកញ្ញា ឆ្នាំ២០២៤ ដែលជាក្រុមតែមួយជាមួយគណនី Fa Fang, Ka Ka និង La Lu ដែលត្រូវបានរកឃើញការបង្ហោះមតិយោបល់ឆ្លងកាត់ទំព័ររបស់អង្គការ CENTRAL, Comfrel និងអង្គការដទៃទៀត។ ដោយឡែក គណនី Pov Hour គឺស្ថិតនៅក្នុងបណ្តុំគណនីបង្កើតឡើងកាលពីខែធ្នូ ឆ្នាំ២០២៤ ដែលជាក្រុមតែមួយជាមួយគណនី Khun Gikeng។ ចំណុចនេះបានបញ្ជាក់អះអាងថា បណ្តាញមិនពិតប្រាកដដដែលនេះ ក៏កំពុងធ្វើសកម្មភាពនៅលើទំព័រប្រជាកាសែតផងដែរ ទោះបីជាចំនួនមតិយោបល់មិនពិតប្រាកដមានកម្រិតទាបខ្លាំងក៏ដោយ។

ចំនួនដ៏តិចតួចនៃមតិយោបល់មិនពិតប្រាកដនេះ អាចពន្យល់ដោយផ្អែកលើមូលហេតុពីរយ៉ាង។ ទីមួយ ប្រជាកាសែតគឺជាស្ថាប័នដែលទើបតែបង្កើតថ្មី ហើយមិនទាន់ក្លាយជាគោលដៅវាយប្រហារអាទិភាពខ្ពស់សម្រាប់យុទ្ធនាការនេះនៅឡើយទេ។ ទីពីរ ព្រឹត្តិការណ៍ទិវាពលកម្មអន្តរជាតិនេះ ត្រូវបានរៀបចំឡើងដោយបណ្តាអង្គការសង្គមស៊ីវិលមួយចំនួនដែលស្ថិតនៅក្នុងការសិក្សាស្រាវជ្រាវនេះស្រាប់។ យុទ្ធនាការនេះផ្តោតសំខាន់ទៅលើអង្គការដែលធ្វើការងារតស៊ូមតិ (Advocacy organizations) មិនមែនផ្តោតលើស្ថាប័នសារព័ត៌មានដែលចុះផ្សាយព័ត៌មានជុំវិញបញ្ហាដដែលនោះឡើយ។ វត្តមានរបស់គណនីដដែលៗទាំងនេះនៅលើទំព័រប្រជាកាសែត បានបញ្ជាក់ឱ្យឃើញថា យុទ្ធនាការនេះបានតាមដានរាល់ព្រឹត្តិការណ៍នានាដែលមានការពាក់ព័ន្ធនឹង

សង្គមស៊ីវិល ប៉ុន្តែពួកគេបានតម្រង់ការវាយប្រហារភាគច្រើនទៅលើតែអង្គការណាដែលធ្វើការតស៊ូមតិដោយផ្ទាល់សម្រាប់សិទ្ធិកម្មករតែប៉ុណ្ណោះ។

# ៤. ការវិភាគអន្តរអង្គការ (Cross-Organization Analysis)

## ៤.១ ក្រុមគណនីមិនពិតប្រាកដដែលធ្វើការសហការគ្នា

ការរកឃើញដ៏សំខាន់មួយនៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺការរកឃើញថាមានក្រុមគណនីមិនពិតប្រាកដ (Inauthentic accounts) ដដែលៗ កំពុងធ្វើសកម្មភាពយ៉ាងសកម្មនៅលើទំព័ររបស់អង្គការសង្គមស៊ីវិលជាច្រើនក្នុងពេលតែមួយ។ គណនីដដែលៗទាំងនោះ ត្រូវបានរកឃើញថាបានបង្ហោះសារមិនពិតប្រាកដនៅលើអត្ថបទបង្ហោះរបស់សមាគមអាដហុក (Adhoc) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) អង្គការសង់ត្រាល់ (CENTRAL) អង្គការកំហ្វ្រែល (Comfrel) និងអង្គការលីកាដូ (LICADHO) ក្នុងអំឡុងពេលដូចគ្នា។ តារាងខាងក្រោមនេះបង្ហាញពីឧទាហរណ៍ដែលត្រូវបានជ្រើសរើសនៃគណនីដែលត្រូវបានស្គាល់ អង្គការ និងអត្ថបទបង្ហោះដែលពួកគេបានលេចមុខ ក៏ដូចជាមតិយោបល់របស់ពួកគេ៖

| ឈ្មោះគណនី | អង្គការ | មតិយោបល់ |
|---|---|---|
| ឆោម លីហេង | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ករណីណាហ្គាវើលដ៍) | ក្រសួងក៏ដូចរដ្ឋាភិបាល<br>ការពារផលប្រយោជន៍បងប្អូនទាំងអស់ |
| ឆោម លីហេង | អង្គការសង់ត្រាល់ (យុទ្ធសាស្ត្រ «ក្រសួងដោះស្រាយរួច») | ក្រសួងបានចាត់វិធានការដោះស្រាយករណីនេះរួចរាល់ហើយ |
| ឆោម លីហេង | អង្គការកំហ្វ្រែល (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | ឱកាសការងារមានស្រាប់<br>សូមទំនាក់ទំនងទៅលេខ ១២៩៧ |
| Pozz Nang | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ករណីណាហ្គាវើលដ៍) | រឿងបានដោះស្រាយចប់តាមនិតិវិធីហើយ |
| Pozz Nang | អង្គការសង់ត្រាល់ (យុទ្ធសាស្ត្រ «ក្រសួងដោះស្រាយរួច») | សូមជម្រាបថា<br>បញ្ហានេះត្រូវបានដោះស្រាយរួចរាល់ហើយដោយក្រសួង |
| Pozz Nang | អង្គការកំហ្វ្រែល (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | ១២៩៧<br>ជាជំនួយសម្រាប់អ្នកកំពុងស្វែងរកការងារ |
| Oun Jing | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ករណីណាហ្គាវើលដ៍) | សហជីពដែលធ្វើខុសច្បាប់ត្រូវទទួលទោសតាមច្បាប់ |

| | | |
|---|---|---|
| Oun Jing | អង្គការសង់ត្រាល់ (ការវាយប្រហារលើរបាយការណ៍ស្រាវជ្រាវ) | ពលករមកពីថៃភ្លាម ទទួលបានការងារធ្វើភ្លាមព្រោះក្រសួងការងារ |
| Oun Jing | អង្គការកំប្រែហ្វូល (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | សូមផ្សព្វផ្សាយឱកាសការងារជំនួសការផ្សាយពាក្យចចាមអារ៉ាម |
| Ben Zø | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ករណីណាហ្គាវើលដ៍) | បើថាក្រុមហ៊ុនមិនបើកប្រាល់សំណង ចុះរយៈពេលច្រើនឆ្នាំ ចាយលុយបរទេស |
| Ben Zø | អង្គការសង់ត្រាល់ (ការវាយប្រហារលើរបាយការណ៍ស្រាវជ្រាវ) | ទិន្នន័យមិនគ្រប់គ្រាន់ ដើម្បីបង្ហាញស្ថានភាពពិត |
| Ben Zø | អង្គការកំប្រែហ្វូល (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | ការងារនៅក្នុងប្រទេសយើងមានច្រើនណាស់ សូមបងប្អូនកុំអស់សង្ឃឹម |
| San Rachany | អង្គការសង់ត្រាល់ (ការវាយប្រហារលើរបាយការណ៍ស្រាវជ្រាវ) | ស្រាវជ្រាវមិនត្រឹមត្រូវផងចេះតែផុសអោយគេយល់ច្រឡំ |
| San Rachany | អង្គការសង់ត្រាល់ (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | ការងារនៅក្នុងស្រុកកំពុងតែបើកច្រើន សូមទំនាក់ទំនង ១២៩៧ |
| San Rachany | អង្គការកំប្រែហ្វូល (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | លេខ ១២៩៧ គឺជាលេខទំនាក់ទំនងសម្រាប់ស្វែងរកការងារ |
| Pirun Choem | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ករណីណាហ្គាវើលដ៍) | តើកញ្ញាហ៊ានទទួលឬបញ្ជាក់ ដែលទេថា លុយកញ្ញាបានមកនេះ បានមកពីបរទេស |
| Pirun Choem | អង្គការសង់ត្រាល់ (ការវាយប្រហារលើរបាយការណ៍ស្រាវជ្រាវ) | ពលករដែលត្រឡប់មកពីប្រទេសសៀមច្រើនណាស់ ដែលមកដល់ខ្មែរហើយ ទទួលបានការងារ |
| Khun Gikeng | អង្គការសង់ត្រាល់ (យុទ្ធសាស្ត្រ «ក្រសួងដោះស្រាយរួច») | ក្រសួងដោះស្រាយលើករណីនេះរួចរាល់ហើយ |
| Khun Gikeng | អង្គការសង់ត្រាល់ (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | ដើម្បីទទួលបានការងារ សូមទាក់ទងលេខ ១២៩៧ |
| Ban Chansela | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ករណីណាហ្គាវើលដ៍) | ការចោទប្រកាន់របស់ក្រុមសហជីព គឺមិនពិតនោះទេ ព្រោះសហជីពផ្សេងគោរពច្បាប់ |

| | | |
|---|---|---|
| Ban Chansela | អង្គការសង់ត្រាល់ (ការវាយប្រហារលើរបាយការណ៍ស្រាវជ្រាវ) | ការស្រាវជ្រាវនេះមិនត្រឹមត្រូវបានភាពជាក់ស្ដែងទេ |
| Ban Chansela | អង្គការសង់ត្រាល់ (ការសម្រុកបង្ហោះខ្សែទូរស័ព្ទ ១២៩៧) | ១២៩៧ ជាលេខសម្រាប់ជួយបងប្អូនរកការងារ |

*តារាងទី៩៖ គណនីមិនពិតប្រាកដដែលត្រូវបានជ្រើសរើស និងរកឃើញនៅលើទំព័ររបស់អង្គការសង្គមស៊ីវិលជាច្រើន*

តារាងខាងលើនេះបានបង្ហាញឱ្យឃើញថា គណនីដដែលៗទាំងនោះបានបង្ហោះសារខុសៗគ្នាតាមប្រភេទផ្សេងៗគ្នាឆ្លងកាត់អង្គការខុសៗគ្នា ដោយវាអាស្រ័យទៅលើប្រធានបទនៃអត្ថបទបង្ហោះនីមួយៗ។ ជាក់ស្ដែង នៅលើអត្ថបទបង្ហោះរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ដែលនិយាយអំពីវិវាទការងារ ពួកគេបានបង្ហោះសារដែលមាននិន្នាការគាំទ្រក្រុមហ៊ុន ឬគាំទ្ររដ្ឋាភិបាល។ នៅលើអត្ថបទបង្ហោះរបស់អង្គការសង់ត្រាល់ (CENTRAL) ដែលនិយាយអំពីពលករចំណាកស្រុក ពួកគេបានសម្រុកបង្ហោះសារផ្សព្វផ្សាយអំពីខ្សែទូរស័ព្ទបន្ទាន់រកការងារធ្វើលេខ ១២៩៧។ ចំណែកឯនៅលើអត្ថបទបង្ហោះរបស់អង្គការសង់ត្រាល់ (CENTRAL) ណាដែលនិយាយអំពីរបាយការណ៍ស្រាវជ្រាវវិញ ពួកគេបានប្រើប្រាស់ភាសាបែបការរិះគន់ផ្នែកការសិក្សាស្រាវជ្រាវ ឬបែបសិក្សាធិការ (Academic-sounding criticism)។ នេះបញ្ជាក់ឱ្យឃើញថា យុទ្ធនាការនេះបានប្រើប្រាស់នូវសំណុំសារឆ្លើយតបដែលត្រូវបានរៀបចំផែនការទុកជាមុន ទៅតាមប្រភេទខ្លឹមសារផ្សេងៗគ្នារបស់អង្គការសង្គមស៊ីវិល។

## ៤.២ បញ្ជីនៃយុទ្ធសាស្ត្រដែលត្រូវបានប្រើប្រាស់

យុទ្ធសាស្ត្រទាំងប្រាំបី (៨) ដែលត្រូវបានរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ អាចត្រូវបានបែងចែកជាក្រុមទៅតាមគោលដៅចម្បងៗចំនួនបី (៣) រួមមាន៖

### គោលដៅ ក៖ ការទប់ស្កាត់មហាជនមិនឱ្យមានការព្រួយបារម្ភ

- យុទ្ធសាស្ត្រ «ក្រសួងបានដោះស្រាយរួចរាល់» គឺជារបៀបប្រាប់ទៅកាន់មហាជនថា បញ្ហាត្រូវបានដោះស្រាយរួចរាល់ហើយ ដូច្នេះពួកគេមិនគួរមានការព្រួយបារម្ភនោះឡើយ។
- ការចោទសួរលើរបាយការណ៍នៃការស្លាប់ គឺជារបៀបចោទសួរដេញដោលថា តើករណីស្លាប់ដែលបានរាយការណ៍នោះ ជាការពិតឬយ៉ាងណា។
- «កុំចែកចាយព័ត៌មានដែលបង្កផលប៉ះពាល់» គឺជារបៀបប្រាប់ទៅកាន់អង្គការសង់ត្រាល់ (CENTRAL) ឱ្យបញ្ឈប់ការបង្ហោះសារ ឬព័ត៌មានទាំងនោះ។

### គោលដៅ ខ៖ ការបង្ខូចកេរ្តិ៍ឈ្មោះរបស់អង្គការសង្គមស៊ីវិល

- ការរិះគន់មិនពិតប្រាកដ (Inauthentic academic criticism) - ការប្រើប្រាស់ភាសាបែបបច្ចេកទេស ឬបែបការសិក្សាស្រាវជ្រាវ ដើម្បីធ្វើឱ្យរបាយការណ៍ស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលមើលទៅដូចជាមិនមានភាពហ្មត់ចត់ និងមិនអាចយកជាការបាន។

- ការបិទស្លាកប្រភពព័ត៌មានថាជា «វិទ្យុប្រឆាំង» - ការចោទប្រកាន់ និងហៅស្ថាប័នព័ត៌មានឯករាជ្យ (ដូចជា វិទ្យុបារាំងអន្តរជាតិ RFI ជាភាសាខ្មែរ) ថាជាស្ថានីយវិទ្យុរបស់ក្រុមប្រឆាំង ដើម្បីកាត់បន្ថយតម្លៃនៃព័ត៌មានដែលយកមកស្រង់សម្ដី។
- ការចោទប្រកាន់រឿងទទួលបានជំនួយពីបរទេស - ការវាយប្រហារដោយលើកឡើងថា អង្គការទាំងនោះទទួលបានប្រាក់ឈ្នួល ឬស្ថិតនៅក្រោមបញ្ជារបស់ភ្នាក់ងារបរទេស ដើម្បីធ្វើសកម្មភាពប្រឆាំងនឹងផលប្រយោជន៍ជាតិ។
- ការយកឈ្មោះរបស់អង្គការមកប្រើប្រាស់ដើម្បីផ្សព្វផ្សាយសាររបស់រដ្ឋាភិបាល - ការបង្កើតមតិយោបល់ដោយបន្លំ ឬលួចប្រើប្រាស់ឈ្មោះរបស់អង្គការផ្ទាល់ ក្នុងគោលបំណងបង្ហោះសារគាំទ្រគោលនយោបាយរដ្ឋាភិបាល ដែលធ្វើឱ្យមហាជនមានការភាន់ច្រឡំលើជំហររបស់អង្គការ។

### គោលដៅ គ៖ ការជំនួសសាររបស់អង្គការសង្គមស៊ីវិល ដោយសាររបស់រដ្ឋាភិបាល

- **ការសម្រុកបង្ហោះលេខទូរស័ព្ទបន្ទាន់រកការងារធ្វើ ១២៩៧/១២៨៦ -** ការសម្រុកបង្ហោះសារផ្សព្វផ្សាយអំពីខ្សែទូរស័ព្ទបន្ទាន់រកការងារធ្វើរបស់ក្រសួងនៅលើគ្រប់ប្រភេទអត្ថបទបង្ហោះទាំងអស់ (ទោះជាអត្ថបទនោះមិនពាក់ព័ន្ធនឹងការរកការងារធ្វើក៏ដោយ) ដើម្បីបង្វែរអារម្មណ៍មហាជន និងបំបិទព័ត៌មានដើម។
- **រឿងរ៉ាវជោគជ័យផ្ទាល់ខ្លួនមិនពិតប្រាកដ -** ការប្រឌិតរឿងរ៉ាវកុហកអំពីការទទួលបានការងារធ្វើ និងភាពជោគជ័យក្នុងជីវិត តាមរយៈការប្រើប្រាស់សេវាដោះស្រាយការងាររបស់រដ្ឋាភិបាល ដើម្បីបង្កើតរូបភាពវិជ្ជមានសិប្បនិម្មិត។
- **យុទ្ធសាស្ត្រ «បង្រៀនមនុស្សឱ្យចេះស្ទូចត្រី» -** ការជជែកដេញដោលទាស់ទែងដោយលើកឡើងថា ការផ្ដល់ជំនួយជាស្បៀងអាហារ (ដូចជាការជួយឧបត្ថម្ភរបស់សង្គមស៊ីវិល) គួរតែត្រូវបានជំនួសមកវិញដោយការណែនាំ ឬការបញ្ជូនទៅរកការងារធ្វើវិញ ទើបជាការត្រឹមត្រូវ។
- **យុទ្ធសាស្ត្រ «សេរីភាពក្នុងការបង្កើតសមាគមមានរួចស្រេចឡាញ់ទៅហើយ» -** ការបង្កើតមតិយោបល់ដើម្បីបដិសេធចំពោះរាល់ការលើកឡើងអំពីការរឹតត្បិត ឬការធ្វើទុក្ខបុកម្នេញលើសហជីព ដោយអះអាងថាសេរីភាពទាំងនេះត្រូវបានអនុវត្តពេញលេញហើយនៅក្នុងប្រទេស។

### ៤.៣ ភស្តុតាងនៃសំណុំសារដែលត្រូវបានរៀបចំទុកជាមុន

ភស្តុតាងដ៏ច្បាស់ក្រឡែតមួយទៀតគឺ ឃ្លាអត្ថបទដូចៗគ្នាទាំងស្រុងបានលេចឡើងនៅលើអត្ថបទបង្ហោះខុសៗគ្នា ដែលត្រូវបានបង្ហោះដាច់ពីគ្នារាប់សប្ដាហ៍ លើប្រធានបទខុសគ្នាស្រឡះ និងប្រើប្រាស់ដោយគណនីមិនដូចគ្នាឡើយ។ តារាងខាងក្រោមនេះបង្ហាញពីសារដែលត្រូវបានរកឃើញ និងបញ្ជាក់ថាមានការយកទៅប្រើប្រាស់ឆ្លងកាត់អត្ថបទបង្ហោះផ្សេងៗគ្នា (Cross-post messages) ដោយមានភ្ជាប់ទាំងអត្ថបទដើមជាភាសាខ្មែរ និងការបកប្រែជាភាសាអង់គ្លេស៖

| មតិយោបល់ | រកឃើញក្នុងការបង្ហោះ | ចំនួន ដង ដែលបានបង្ហោះ |
|---|---|---|

| | | |
|---|---|---|
| ការងារនៅក្នុងប្រទេសផ្តល់ឱកាសសម្រាប់អភិវឌ្ឍជំនាញផ្ទាល់ខ្លួន | 3 posts | 1 per post |
| បងប្អូនដែលត្រលប់មកពីក្រៅប្រទេសអាចស្វែងរកការងារតាមលេខ ១២៩៧ | 4 posts | 4 times |
| ការស្រាវជ្រាវនេះមិនត្រឹមត្រូវបានភាពជាក់ស្តែងទេ | 2 posts | 2 times |
| ខ្ញុំជាអតីតពលករពីប្រទេសថៃ ហើយខ្ញុំមានការងារធ្វើពីការទាក់ទងតាម ១២៩៧ | 3 posts | 2 times |
| ពលករខ្មែរវិលត្រឡប់មកដើម្បីរកការងារក្នុងស្រុក តែវិទ្យុប្រឆាំងសុទ្ធតែមើលរំលង | 2 posts | 1 per post |
| ក្រសួងការងារពិតជាជួយ ទំនាក់ទំនង ១២៩៧ ដើម្បីទទួលបានការងារ | 5 or more posts | 3 times |
| ការងារនៅក្នុងប្រទេសយើងមានច្រើនណាស់ សូមបងប្អូនកុំអស់សង្ឃឹម | 4 or more posts | 4 times |
| ទិន្នន័យមិនគ្រប់គ្រាន់ ដើម្បីបង្ហាញស្ថានភាពពិត | 3 posts | 4 times |

*តារាងទី១០៖ សំណុំសារដែលត្រូវបានរៀបចំទុកជាមុន និងរកឃើញនៅលើអត្ថបទបង្ហោះខុសៗគ្នា*

## ៤.៤ ការវិភាគបណ្តាញគណនី

បន្ថែមទៅលើការវិភាគខ្លឹមសារនៃមតិយោបល់ ការសិក្សាស្រាវជ្រាវនេះក៏បានពិនិត្យមើលទៅលើប្រវត្តិរូប (Profiles) នៃគណនីហ្វេសប៊ុក (Facebook accounts) របស់អ្នកបញ្ចេញមតិយោបល់ ឆ្លងកាត់អង្គការទាំងប្រាំមួយ (៦) ដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគយ៉ាងលម្អិត។ សម្រាប់គណនីនីមួយៗដែលបានបង្ហោះសារនៅលើទំព័រដែលស្ថិតក្រោមការតាមដាន ទិន្នន័យត្រូវបានប្រមូលផ្តុំទៅលើ កាលបរិច្ឆេទនៃការបង្កើតគណនី (Account creation date) និង កាលបរិច្ឆេទនៃការបង្ហោះសារផ្ទាល់ខ្លួនចុងក្រោយបង្អស់ (Date of the last personal post)។ ទិន្នន័យទាំងពីរចំណុចនេះ ត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណគណនីទាំងឡាយណា ដែលបង្ហាញពីសញ្ញាណនៃការបង្កើតឡើងក្នុងគោលបំណងចម្បងសម្រាប់សម្រុកបញ្ចេញមតិយោបល់ក្នុងចំនួនយ៉ាងច្រើន (Mass commenting) ជាជាងការប្រើប្រាស់បណ្តាញសង្គមតាមលក្ខណៈធម្មជាតិ និងពិតប្រាកដ។

វិធីសាស្ត្រស្រាវជ្រាវ

គណនីមួយនឹងត្រូវរាយចំណាំ ឬកំណត់សញ្ញាសម្គាល់ (Flagged) ថាមានភាពមិនប្រក្រតី ប្រសិនបើវាបំពេញតាមលក្ខវិនិច្ឆ័យចាប់ពីពីរ (២) ឬច្រើនជាងនេះ ក្នុងចំណោមលក្ខវិនិច្ឆ័យដូចខាងក្រោម៖

1. **កាលបរិច្ឆេទបង្កើតគណនីថ្មីៗ៖** គណនីត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០២៤, ២០២៥ ឬ ២០២៦ ដែលមានន័យថាវាជាគណនីទើបតែបង្កើតថ្មីៗ។
2. **គណនីខ្វះសកម្មភាពផ្ទាល់ខ្លួន (Inactive)៖** ការបង្ហោះសារ ឬខ្លឹមសារផ្ទាល់ខ្លួនចុងក្រោយបង្អស់ (Last personal post) បានធ្វើឡើងតាំងពីជាងបួនសប្តាហ៍មុន។

3. **គណនីមិនដែលបង្ហោះអ្វីសោះ (Zero personal activity)៖** ការបង្ហោះសារផ្ទាល់ខ្លួនចុងក្រោយបង្អស់ត្រូវបានប្រព័ន្ធកត់ត្រាថា «០ នាទីមុន» (Zero minutes ago) ដែលមានន័យថា គណនីនោះប្រហែលជាមិនដែលបង្កើតការបង្ហោះផ្ទាល់ខ្លួនណាមួយទាល់តែសោះ ហើយត្រូវបានយកមកប្រើប្រាស់តែមួយមុខគត់សម្រាប់ដើររុញបញ្ចេញមតិយោបល់ (Comment)។

បន្ថែមលើនេះ គណនីទាំងនោះនឹងត្រូវចាត់ចូលជាក្រុម ឬបណ្តុំតែមួយ (Clusters) ប្រសិនបើរកឃើញថាមានគណនីចាប់ពីពីរ ឬច្រើនជាងនេះ ដែលស្ថិតនៅក្នុងផ្នែកបញ្ចេញមតិ (Comment section) តែមួយ ត្រូវបានបង្កើតឡើងនៅក្នុងខែ និងឆ្នាំតែមួយ (Same calendar month)។ ការរកឃើញបណ្តុំគណនីដែលបង្កើតក្នុងខែជាមួយគ្នានេះ ឆ្លុះបញ្ចាំងឱ្យឃើញពី «ព្រឹត្តិការណ៍បង្កើតគណនីជាកញ្ចប់ ឬជាស៊េរី» (Batch creation event) ដែលគណនីជាច្រើនត្រូវបានបង្កើតឡើងក្នុងពេលតែមួយ ក្នុងនាមជាផ្នែកមួយនៃប្រតិបត្តិការដែលបានរៀបចំផែនការទុកជាមុន។

ហេតុអ្វីបានជាជ្រើសរើសរយៈពេល ៤ សប្តាហ៍? រយៈពេលបួនសប្តាហ៍ត្រូវបានជ្រើសរើសជាកម្រិតកំណត់សម្រាប់វាស់វែងភាពមិនសកម្ម (Inactivity threshold) ពីព្រោះអ្នកប្រើប្រាស់ហ្វេសប៊ុកសកម្មតាមលក្ខណៈធម្មតា ជាទូទៅតែងតែបង្ហោះខ្លឹមសារផ្ទាល់ខ្លួនយ៉ាងហោចណាស់ម្តងក្នុងមួយខែ។ ដូច្នេះ គណនីណាដែលមិនបានបង្ហោះខ្លឹមសារផ្ទាល់ខ្លួនសោះលើសពីបួនសប្តាហ៍ ប៉ុន្តែនៅតែបន្តដើរខមិនយ៉ាងសកម្មលើទំព័ររបស់អង្គការសង្គមស៊ីវិល គឺមានឱកាសខ្ពស់ណាស់ដែលគណនីនោះត្រូវបានប្រើប្រាស់ក្នុងគោលបំណងចម្បងសម្រាប់ការសម្រុកបញ្ចេញមតិយោបល់តាមគោលដៅ ជាងការប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួនពិតប្រាកដ។ ទម្រង់បែបបទ (Pattern) នេះគឺជាសញ្ញាណដ៏រឹងមាំមួយដែលបញ្ជាក់ថា គណនីទាំងនោះត្រូវបានបង្កើតឡើងដើម្បីចូលរួមក្នុងយុទ្ធនាការសម្រុកបញ្ចេញមតិយោបល់ដែលសហការគ្នាជាប្រព័ន្ធ (Coordinated commenting campaign)។

### ***សេចក្តីសង្ខេបនៃការរកឃើញ***

| ឈ្មោះអង្គការ | ចំនួនគណនីដែលបានពិនិត្យ | គណនីដែលមានសញ្ញាណសង្ស័យ | ភាគរយគណនីសង្ស័យ | ចំនួនបណ្តុំគណនីដែលរកឃើញ |
|---|---|---|---|---|
| សមាគមអាដហុក (Adhoc) | ~២២០ | ៦៨ | ៣១% | ១១ |
| មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | ~៩០ | ២១ | ២៣% | ៥ |
| អង្គការសង់ត្រាល់ (CENTRAL - ៩០ អត្ថបទបង្ហោះ) | ~៨០០+ | ៤០០+ | ៥០-៩១% | ១០០+ |
| អង្គការកំហ្វ្រែល (Comfrel) | ២៩២ | ១៨៥ | ៦៣% | ៧ |
| អង្គការលីកាដូ (Licadho) | ២,២២០ | ៧១ | ៣% | ១៧ |

| | | | | |
|---|---|---|---|---|
| ប្រជាកាសែត - Prochea Kaset | ៨៣៩ | ៤៨ | ៦% | ១២ |

*តារាងទី១១៖ សេចក្ដីសង្ខេបលទ្ធផលនៃការវិភាគគណនីតាមស្ថាប័ន*

## *លំនាំសំខាន់ដែលបានរកឃើញ*

ការវិភាគបណ្តាញគណនីបានរកឃើញនូវទម្រង់លំនាំច្បាស់លាស់មួយចំនួន ដែលជួយបញ្ជាក់បន្ថែមលើលទ្ធផលទទួលបានពីការវិភាគខ្លឹមសារនៃមតិយោបល់។ ទម្រង់លំនាំទាំងនេះបង្ហាញថា បណ្តាញគណនីមិនពិតប្រាកដទាំងនោះ មិនត្រឹមតែមានការចាត់តាំងរៀបចំជាប្រព័ន្ធលើខ្លឹមសារសារឆ្លើយតបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការរៀបចំផែនការយ៉ាងហត់ចត់ក្នុងការបង្កើត និងការគ្រប់គ្រងគណនីទាំងនោះទៀតផង។

### លំនាំទី១៖ ការបង្កើតគណនីជាកញ្ចប់ក្នុងទ្រង់ទ្រាយធំ (Large-Scale Batch Account Creation)

ឆ្លងកាត់ទំព័ររបស់អង្គការសង់ត្រាល់ (CENTRAL) និងអង្គការកំហ្វ្រែល (Comfrel) បណ្តុំគណនីដែលបង្កើតក្នុង ខែធ្នូ ឆ្នាំ២០២៤ គឺជាកញ្ចប់គណនីតែមួយធំជាងគេបង្អស់ដែលត្រូវបានរកឃើញនៅក្នុងការសិក្សានេះ។

- នៅអង្គការកំហ្វ្រែល (Comfrel)៖ មានគណនីរហូតដល់ទៅ ៩៩ ត្រូវបានបង្កើតឡើងក្នុងខែធ្នូ ឆ្នាំ ២០២៤ តែមួយ។
- នៅអង្គការសង់ត្រាល់ (CENTRAL)៖ គណនីដែលបង្កើតក្នុងខែធ្នូ ឆ្នាំ២០២៤ ដដែលៗទាំងនេះ បានលេចឡើងនៅលើអត្ថបទបង្ហោះជាច្រើនដង។
- ទម្រង់នៃការដាក់ឈ្មោះ៖ គណនីភាគច្រើនបានប្រើប្រាស់ទម្រង់ឈ្មោះដដែលៗពីរដង ដូចជា Achariya Achariya, Chakra Chakra, និង Ary Ary ដែលទម្រង់ដាក់ឈ្មោះបែបនេះ គឺជាសញ្ញាណសម្គាល់នៃការបង្កើតគណនីដោយស្វ័យប្រវត្ត ឬការបង្កើតគណនីក្នុងចំនួនច្រើនព្រមៗគ្នា (Bulk creation)។
- ការបង្កើតក្នុងថ្ងៃតែមួយ (ខែកញ្ញា ឆ្នាំ២០២៤)៖ ស្រដៀងគ្នានេះដែរ នៅក្នុងខែកញ្ញា ឆ្នាំ២០២៤ មានគណនីមួយចំនួនត្រូវបានបង្កើតឡើងក្នុងថ្ងៃតែមួយចំថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ រួមមានគណនីឈ្មោះ Ah DyDy, Meng Tong, Na Roth, និង Meng Seu។ គណនីទាំងនេះបានលេចឡើងឆ្លងកាត់អត្ថបទបង្ហោះជាច្រើនរបស់ CENTRAL និងនៅក្នុងប្រអប់បញ្ចេញមតិនៃទំព័រប្រជាកាសែត - Prochea Kaset ផងដែរ។

### លំនាំទី២៖ ការផ្អាកសកម្មភាពព្រមៗគ្នា (Synchronized Dormancy)

បណ្តុំគណនីជាច្រើនបានផ្អាកសកម្មភាព ឬក្លាយជាគណនីអសកម្ម (Inactive) នៅក្នុងពេលតែមួយយ៉ាងស៊ីសង្វាក់គ្នា។ ជាឧទាហរណ៍ នៅលើអត្ថបទបង្ហោះរបស់ CENTRAL អំពីវេទិកាស្រាវជ្រាវរបស់វិទ្យុអាស៊ីសេរី (RFA) និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បណ្តុំគណនីខែតុលា ឆ្នាំ ២០២៤ ចំនួន ១២ គណនី និងបណ្តុំគណនីខែវិច្ឆិកា ឆ្នាំ២០២៤ ចំនួន ២៥ គណនី សុទ្ធតែបង្ហាញពីពេលវេលាផ្អាកសកម្មភាពចុងក្រោយ (Last-active timestamp) ដូចគ្នាបេះបិទគឺតាំងពី «១៣ សប្តាហ៍មុន»។ នេះមានន័យថា គណនីសរុបចំនួន ៣៧ ដែលមកពីកញ្ចប់បង្កើតខុសគ្នាពីរ បានបញ្ឈប់ការបង្ហោះសារក្នុងពេលតែ

មួយចំថ្ងៃតែមួយ។ ភាពអសកម្មព្រមៗគ្នានេះ គឺជាភស្តុតាងដ៏រឹងមាំនៃការគ្រប់គ្រងពីមជ្ឈមណ្ឌលតែមួយ (Centralized management) ដែលបុគ្គលម្នាក់ ឬក្រុមតែមួយជាអ្នកបញ្ជាគណនីទាំងនេះ និងជាអ្នកសម្រេចចិត្តថាពេលណាត្រូវប្រើប្រាស់ និងពេលណាត្រូវបញ្ឈប់។

**លំនាំទី៣៖ បណ្តាញគណនីឆ្លងកាត់អង្គការផ្សេងៗគ្នា (Cross-Organization Account Network)**

- គណនីដដែលៗបានលេចមុខឆ្លងកាត់ទំព័ររបស់អង្គការសង្គមស៊ីវិលជាច្រើន។
- គណនីឈ្មោះ Pirun Choem និង Veha Seng ដែលត្រូវបានបង្កើតឡើងក្នុងថ្ងៃតែមួយគឺថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ បានលេចឡើងនៅលើអត្ថបទបង្ហោះរបស់ CENTRAL, អង្គការកំហ្វ្រែល (Comfrel) និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)។
- គណនីឈ្មោះ Khun Gikeng បង្កើតឡើងនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ បានលេចឡើងនៅលើ CENTRAL (ច្រើនអត្ថបទបង្ហោះ), Comfrel និងប្រជាកសិករ (ProcheaKaset)។
- គណនីឈ្មោះ Fa Fang, Ka Ka, និង La Lu ដែលត្រូវបានបង្កើតក្នុងខែកញ្ញា ឆ្នាំ២០២៤ ទាំងអស់គ្នា បានលេចមុខនៅក្នុងប្រអប់បញ្ចេញមតិនៃទំព័រ Comfrel និងប្រជាកសិករ (ProcheaKaset)។
- គណនីឈ្មោះ Oun Jing បានលេចឡើងនៅលើអត្ថបទបង្ហោះរបស់ CENTRAL និង Comfrel។

**លំនាំទី៤៖ ការចិញ្ចឹមគណនី និងបន្តបង្កើតគណនីថ្មីៗ (Ongoing Network Maintenance)**

ការសិក្សាស្រាវជ្រាវបានរកឃើញគណនីដែលទើបតែបង្កើតថ្មីៗនៅក្នុងចុងឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦។ គណនីឈ្មោះ Burin Yujii ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦ និងគណនីឈ្មោះ Aŕh Stæv ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦។ គណនីទាំងនេះស្ថិតក្នុងចំណោមគណនីថ្មីបំផុតនៅក្នុងសំណុំទិន្នន័យ។ គណនីទាំងពីរនេះបានក្លាយជាគណនីអសកម្មទៅហើយ បន្ទាប់ពីមានសកម្មភាពត្រឹមតែពីរបីសប្តាហ៍ប៉ុណ្ណោះ។ នេះបង្ហាញឱ្យឃើញថា ម្ចាស់ប្រតិបត្តិការបណ្តាញ (Network operator) នៅតែបន្តបង្កើតគណនីថ្មីៗ និងបន្ថែមពួកវាទៅក្នុងប្រតិបត្តិការ សូម្បីតែនៅក្នុងអំឡុងពេលដែលការសិក្សាស្រាវជ្រាវនេះកំពុងធ្វើការតាមដានក៏ដោយ។

**លំនាំទី៥៖ ភាពខុសគ្នារវាងអង្គការនីមួយៗ (Difference Between Organizations)**

- CENTRAL និង Comfrel៖ បង្ហាញពីលំនាំ «រលកគណនីរ៉ូបូតផ្អាកសកម្មភាព» (Dormant bot wave pattern) ដែលគណនីត្រូវបានបង្កើតឡើងជាកញ្ចប់ យកមកប្រើប្រាស់សម្រាប់សម្រុកសរសេរមតិយោបល់ រួចក៏ប្រែជាអសកម្មទៅវិញព្រមៗគ្នា។
- Licadho និងប្រជាកាសែត - Prochea Kaset៖ បង្ហាញពីលំនាំខុសប្លែកពីគេ ដោយគណនីដែលទើបបង្កើតថ្មីៗនៅតែបន្តមានសកម្មភាពបង្ហោះយ៉ាងរស់រវើក។ នេះអាចបញ្ជាក់បានថា បណ្តាញតែមួយនេះអាចនឹងកំពុងប្រើប្រាស់យុទ្ធសាស្ត្រខុសគ្នាទៅតាមអង្គការនីមួយៗ ឬគណនីនៅលើទំព័រ Licadho និងប្រជាកាសែត - Prochea Kasetគឺជាតំណាងឱ្យដំណាក់កាលថ្មីមួយទៀតនៃប្រតិបត្តិការ (Newer phase) ដែលមិនទាន់ឈានចូលដល់ដំណាក់កាលផ្អាកសកម្មភាព (Dormant)។

### ***គណនីឆ្លងកាត់អង្គការផ្សេងៗគ្នាដែលត្រូវបានជ្រើសរើស (Selected Cross-Organization Accounts)***

តារាងខាងក្រោមនេះបង្ហាញពីគណនីមួយចំនួនដែលត្រូវបានជ្រើសរើស និងបញ្ជាក់ថាបានលេចឡើងនៅលើទំព័ររបស់អង្គការសង្គមស៊ីវិលជាច្រើន ព្រមទាំងមានភ្ជាប់ជាមួយនូវកាលបរិច្ឆេទនៃការបង្កើតគណនី និងឈ្មោះអង្គការដែលពួកគេបានចូលទៅធ្វើសកម្មភាព។

| ឈ្មោះគណនី | កាលបរិច្ឆេទ ចូលប្រើប្រាស់គណនី | ឈ្មោះអង្គការ | ស្ថានភាព ភាពសកម្មរបស់គណនី |
|---|---|---|---|
| Pirun Choem | ថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០២៥ | CENTRAL, Comfrel, CCHR | អសកម្ម ៥ សប្តាហ៍ |
| Veha Seng | ថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០២៥ | CENTRAL, Comfrel, CCHR | អសកម្ម ២២ សប្តាហ៍ |
| Khun Gikeng | ថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០២៤ | CENTRAL (x4 posts), Comfrel, Prochea Kaset | អសកម្ម ៨ ទៅ ១០ សប្តាហ៍ |
| Cha Li | ថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០២៤ | CENTRAL (x3 posts) | អសកម្ម ៩ សប្តាហ៍ |
| Fa Fang | ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០២៤ | CENTRAL, Comfrel, Prochea Kaset | អសកម្ម ៨ ទៅ ៩ សប្តាហ៍ |
| Ka Ka | ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០២៤ | CENTRAL, Comfrel, Prochea Kaset | អសកម្ម ៨ ទៅ ៩ សប្តាហ៍ |
| La Lu | ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០២៤ | CENTRAL, Comfrel, Prochea Kaset | អសកម្ម ៨ ទៅ ៩ សប្តាហ៍ |
| Oun Jing | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ | CENTRAL (x3 posts), Comfrel | អសកម្ម ២៥ សប្តាហ៍ |
| Pozz Nang | ខែសីហា ឆ្នាំ ២០២៤ | CCHR, CENTRAL, Comfrel, Licadho | អសកម្ម ១០ សប្តាហ៍ |
| Ban Chansela | ខែកញ្ញា ឆ្នាំ២០២៤ | CCHR, CENTRAL, Comfrel | អសកម្ម ៥ សប្តាហ៍ |

*តារាងទី១២៖ គណនីមិនពិតប្រាកដដែលត្រូវបានជ្រើសរើសឆ្លងកាត់អង្គការខុសៗគ្នា*

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ មានគណនីយ៉ាងហោចណាស់ចំនួនប្រាំត្រូវបានបង្កើតឡើងក្នុងថ្ងៃតែមួយ រួមមានគណនីឈ្មោះ Cha Li និង Khun Gikeng។ មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ គណនីថ្មីចំនួនពីរទៀត គឺ Pirun Choem និង Veha Seng ក៏ត្រូវបានបង្កើតឡើងផងដែរ។ ទោះបីជាការត្រូវគ្នានៃកាលបរិច្ឆេទនេះអាចជារឿងចៃដន្យក៏ដោយ ប៉ុន្តែអ្វីដែលសំខាន់ និងគួរឱ្យកត់សម្គាល់នោះគឺទម្រង់លំនាំ (Pattern) នៃសកម្មភាពនេះផ្ទាល់តែម្តង។ នៅពេលដែលគណនីចាស់ៗតាំងពីខែធ្នូ ឆ្នាំ២០២៤ ចាប់ផ្តើមអសកម្ម ឬចាប់ផ្តើ

មរងការចាប់អារម្មណ៍និងតាមដាន គណនីថ្មីៗក៏បានលេចចេញមកជំនួស។ ចំណុចនេះបង្ហាញឱ្យឃើញថា អ្នកបញ្ជាប្រតិបត្តិការបណ្ដាញនេះ មិនមែនកំពុងដំណើរការយុទ្ធនាការតែមួយដងរួចចោលនោះឡើយ។ ពោលគឺមានបុគ្គលណាម្នាក់កំពុងគ្រប់គ្រង និងចាត់ចែងប្រតិបត្តិការនេះយ៉ាងសកម្មជាបន្តបន្ទាប់ទៅតាមពេលវេលា តាមរយៈការបង្កើតគណនីថ្មីៗដើម្បីបន្តដំណើរការយុទ្ធនាការនេះកុំឱ្យដាច់។

## ៥. ការពិភាក្សា

លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យឃើញពីយុទ្ធនាការដែលមានការរៀបចំផែនការ និងការចាត់តាំងជាប្រព័ន្ធ ក្នុងគោលដៅវាយប្រហារលើបណ្ដាអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ មានកត្តាស្នូលមួយចំនួនដែលបញ្ជាក់ថា សកម្មភាពទាំងនេះមិនមែនគ្រាន់តែជាការរិះគន់តាមបណ្ដាញអនឡាញធម្មតានោះឡើយ៖

**ទីមួយ** យុទ្ធនាការនេះមានគោលដៅវាយប្រហារលើអង្គការជាច្រើនក្នុងពេលតែមួយ៖ គណនីដដែលៗបានបង្ហោះសារខុសៗគ្នានៅលើទំព័ររបស់អង្គការផ្សេងៗគ្នាក្នុងថ្ងៃតែមួយ។ សម្រាប់ខ្លឹមសារពាក់ព័ន្ធនឹងការងាររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) គណនីទាំងនោះបានបង្ហោះសារគាំទ្រក្រុមហ៊ុន ឬគាំទ្ររាជរដ្ឋាភិបាល។ ចំពោះអត្ថបទស្ដីពីការធ្វើចំណាកស្រុករបស់អង្គការសង់ត្រាល់ (CENTRAL) គណនីទាំងនោះបានសម្រុកបង្ហោះសារផ្សព្វផ្សាយការងារ ១២៩៧ យ៉ាងគំហុក។ ចំណែកឯអត្ថបទស្ដីពីរបាយការណ៍ស្រាវជ្រាវរបស់ CENTRAL វិញ គណនីទាំងនេះបានប្រើប្រាស់ភាសារិះគន់បែបសារអ្នកសិក្សាស្រាវជ្រាវ។ នេះបង្ហាញថា មានក្រុមតែមួយជាអ្នកដឹកនាំយុទ្ធនាការ ដោយមានសំណុំសារ (comment) ឆ្លើយតបដែលបានព្រាងទុកជាមុន។

**ទីពីរ** យុទ្ធនាការនេះផ្លាស់ប្ដូរយុទ្ធសាស្ត្ររបស់ខ្លួនទៅតាមប្រភេទនៃអត្ថបទបង្ហោះ៖ នៅពេលដែល CENTRAL ចេញផ្សាយលទ្ធផលស្រាវជ្រាវ គណនីទាំងនោះបានប្រើប្រាស់ការរិះគន់បែបស្រាវជ្រាវដែលប្រឌិតឡើង។ នៅពេលដែល CENTRAL ដំណើរការកម្មវិធីអប់រំ គណនីទាំងនោះប្រែមកសម្រុកបង្ហោះសារ ១២៩៧ វិញ។ ចំណុចនេះឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីការរៀបចំផែនការដោយមនុស្សនៅពីក្រោយយុទ្ធនាការនេះ។

**ទីបី** យុទ្ធនាការនេះមានការឆ្លើយតបយ៉ាងរហ័សបំផុត៖ លើអត្ថបទបង្ហោះជាច្រើនរបស់ CENTRAL មតិយោបល់ដំបូងៗគេបង្អស់ គឺសុទ្ធសឹងតែជាសារមិនពិតប្រាកដរបស់យុទ្ធនាការនេះ។ កត្តានេះទាមទារឱ្យមានមនុស្សចាត់តាំងច្បាស់លាស់ក្នុងការអង្គុយតាមដានទំព័ររបស់ CENTRAL និងធ្វើការបង្ហោះសារយ៉ាងលឿន រាល់ពេលដែលមានអត្ថបទថ្មីលេចឡើង។

**ទីបួន** លទ្ធផលទទួលបានពីអង្គការលីកាដូ (Licadho) ក៏គួរឱ្យយកចិត្តទុកដាក់ផងដែរ។ លីកាដូ ទទួលបានមតិយោបល់ចំនួន ២,៣៨៤ ឆ្លងកាត់អត្ថបទបង្ហោះចំនួនបួន ដែលជាចំនួនមានមតិយោបល់ច្រើនជាងគេបង្អស់នៅក្នុងការសិក្សានេះ។ មតិយោបល់ភាគច្រើនទាំងនេះ គឺជាការសម្ដែងចេញពិតៗនូវកំហឹង និងការខកចិត្តរបស់សាធារណជន ជាពិសេសនៅលើអត្ថបទបង្ហោះពាក់ព័ន្ធនឹងការចាប់ខ្លួនប្រជាពលរដ្ឋធម្មតា ចំពោះការបង្ហោះសារលើហ្វេសប៊ុកអំពីជម្លោះព្រំដែនរវាងកម្ពុជា និងថៃ។ នេះបង្ហាញថា នៅពេលដែលអង្គការសង្គមស៊ីវិលរាយការណ៍អំពីបញ្ហាដែលប៉ះពាល់ផ្ទាល់ដល់សេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ សាធារណជននឹងឆ្លើយតបយ៉ាងខ្លាំងក្លា និងដោយពិតប្រាកដ។ ទោះជាយ៉ាងណាក៏ដោយ គណនីមិនពិតប្រាកដមួយចំនួនក៏ត្រូវបានរកឃើញនៅក្នុងប្រអប់បញ្ចេញមតិរបស់លីកាដូផងដែរ ដែលនេះបញ្ជាក់ថា យុទ្ធនាការនេះបានតាមដានអត្ថបទបង្ហោះរបស់លីកាដូ ប៉ុន្តែមិនបានចូលគ្រប់គ្រង ឬគ្របដណ្ដប់ទាំងស្រុងដូចដែលពួកគេបានធ្វើលើទំព័ររបស់អង្គការសង់ត្រាល់នោះឡើយ។

ការវិភាគគណនីនៅក្នុងផ្នែក ៤.៤ បានផ្តល់នូវភស្តុតាងបច្ចេកទេសដែលគាំទ្រដល់រាល់លទ្ធផលផ្អែកលើខ្លឹមសារខាងលើទាំងអស់។ ការរកឃើញគណនីដែលត្រូវបានបង្កើតឡើងក្នុងថ្ងៃតែមួយជាកញ្ចប់ៗ, គណនីដែលបានផ្អាកសកម្មភាពក្នុងពេលតែមួយយ៉ាងស៊ីសង្វាក់គ្នា និងគណនីដដែលៗដែលលេចមុខឆ្លងកាត់អង្គការខុសៗគ្នាចំនួនប្រាំក្នុងពេលតែមួយ សុទ្ធតែបានបញ្ជាក់អះអាងថា យុទ្ធនាការនេះមិនមែនជាទង្វើរបស់បុគ្គលម្នាក់ៗធ្វើឡើងដោយដាច់ឡែកពីគ្នានោះឡើយ។ វាគឺជាប្រតិបត្តិការដែលត្រូវបានគ្រប់គ្រងពីមជ្ឈមណ្ឌលតែមួយ ដោយមានយុទ្ធសាស្ត្រស្របគ្នា មានកញ្ចប់គណនីប្រើប្រាស់រួមគ្នា និងមានការថែទាំបណ្តាញជាប្រចាំ ដែលបានបន្តធ្វើឡើងរហូតមកដល់អំឡុងពេលនៃការតាមដាននៃការសិក្សាស្រាវជ្រាវនេះ។

វត្តមានរបស់គណនីមិនពិតប្រាកដដដែលៗទាំងនេះនៅលើទំព័រប្រជាកាសែត ដែលជាស្ថាប័នសារព័ត៌មានចុះផ្សាយអំពីព្រឹត្តិការណ៍ទិវាពលកម្មអន្តរជាតិដូចគ្នានោះ បានបង្ហាញឱ្យឃើញថា យុទ្ធនាការនេះបានតាមដានរាល់ព្រឹត្តិការណ៍ទាំងឡាយណាដែលមានការផ្សារភ្ជាប់នឹងសង្គមស៊ីវិល ហើយសកម្មភាពរបស់ពួកគេមិនត្រូវបានកម្រិតត្រឹមតែនៅលើទំព័ររបស់អង្គការតស៊ូមតិតែមួយមុខនោះឡើយ។

# ៦. សេចក្តីសន្និដ្ឋាន

ផ្អែកលើការតាមដានអង្គការចំនួនដប់ប្រាំ ព្រមទាំងការវិភាគលម្អិតលើមតិយោបល់ចំនួន ៤,៩០៣ ឆ្លងកាត់អត្ថបទបង្ហោះចំនួន ៥៤ នៅលើទំព័ររបស់អង្គការចំនួនប្រាំមួយ ក្នុងអំឡុងខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៦ ការសិក្សាស្រាវជ្រាវនេះបានឈានដល់សេចក្តីសន្និដ្ឋានដូចខាងក្រោម៖

១. មានបណ្តាញក្រុមគណនីមិនពិតប្រាកដមួយកំពុងសហការគ្នាធ្វើសកម្មភាពឆ្លងកាត់ទំព័ររបស់អង្គការតស៊ូមតើយ៉ាងហោចណាស់ចំនួនប្រាំ និងស្ថាប័នសារព័ត៌មានមួយក្នុងពេលតែមួយ ដោយប្រើប្រាស់សំណុំសារឆ្លើយតបដែលបានព្រាងទុកជាស្រេចទាំងជាភាសាខ្មែរ។

២. យុទ្ធសាស្ត្រមិនពិតប្រាកដចំនួនប្រាំបីខុសៗគ្នាត្រូវបានរកឃើញ។ យុទ្ធសាស្ត្រទាំងនោះមានចាប់តាំងពីទម្រង់សាមញ្ញដូចជា ការសម្រុកបង្ហោះសារដដែលៗជាបណ្តុំ រហូតដល់វិធីសាស្ត្រដែលមានភាពស្មុគស្មាញជាងនេះ ដូចជាការបង្កើតការរិះគន់បែបប្រឌិត និងការយកឈ្មោះរបស់អង្គការសង្គមស៊ីវិលទៅប្រើប្រាស់ដើម្បីផ្សព្វផ្សាយសារគាំទ្ររាជរដ្ឋាភិបាល។

៣. អង្គការសង់ត្រាល់ (CENTRAL) គឺជាស្ថាប័នដែលរងការវាយប្រហារចំគោលដៅខ្លាំងជាងគេបង្អស់ ដោយមានអត្រាមតិយោបល់មិនពិតប្រាកដចន្លោះពី ៧០% ដល់ ៩៨% ឆ្លងកាត់អត្ថបទបង្ហោះចំនួន ៤១។ យុទ្ធនាការនេះរឹតតែមានសន្ទុះខ្លាំងក្លាឡើង នៅពេលដែល CENTRAL បោះពុម្ពផ្សាយរបាយការណ៍ស្រាវជ្រាវ ឬលេចមុខនៅក្នុងវេទិកាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

៤. អង្គការកំហ្វ្រែល (Comfrel) មានចំនួនសារមិនពិតប្រាកដដដែលៗខ្ពស់ជាងគេបំផុត ដោយក្នុងនោះ ៦២% នៃមតិយោបល់ទាំងអស់គឺជាសារចម្លង។ សារដដែលៗទាំងនេះត្រូវបានយកមកប្រើប្រាស់ឆ្លងកាត់អត្ថបទបង្ហោះដែលមានកាលបរិច្ឆេទពីរខុសគ្នា ដែលនេះជាភស្តុតាងបញ្ជាក់ពីប្រតិបត្តិការដែលមានការរៀបចំទុកជាមុន។

៥. អត្ថបទបង្ហោះរបស់អង្គការលីកាដូ (LICADHO) ពាក់ព័ន្ធនឹងការចាប់ខ្លួនលើករណីសេរីភាពក្នុងការបញ្ចេញមតិ ទទួលបានការឆ្លើយតបពិតប្រាកដពីសាធារណជនច្រើនជាងគេ និងមានមតិយោបល់ដែលត្រូវបានកត់ចំណាំ (Flagged comments) ច្រើនជាងគេបំផុត។ អត្ថបទបង្ហោះទាំងនេះបានទាក់ទាញអារម្មណ៍ជាតិនិយមយ៉ាងខ្លាំងក្លាពីសំណាក់មហាជនពិតប្រាកដ ចំពោះស្ថានភាពព្រំដែនកម្ពុជា និងថៃ។

៦. អត្ថបទបង្ហោះរបស់សមាគមអាដហុក (Adhoc) ស្តីពីជម្លោះដីធ្លីនៅខេត្តរតនគិរី មានការប្រើប្រាស់ភាសាធ្ងន់ធ្ងរ និងកាចសាហាវបំផុត ដោយក្នុងនោះត្រូវបានរកឃើញនូវសារគំរាមកំហែងដល់អាយុជីវិត (Death threats) ចំនួន ១២ សារ នៅក្នុងអត្ថបទបង្ហោះទី២ (Post 2)។

៧. អត្ថបទបង្ហោះមួយរបស់ CENTRAL ស្តីពីកម្មករដែលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែនបានទាក់ទាញមតិយោបល់ក្នុងន័យអវិភាពពីសំណាក់គណនីដែលបង្ហាញអត្តសញ្ញាណជាជនជាតិថៃ។ នេះគឺជាការគំរាមកំហែងដាច់ដោយឡែកមួយទៀត ដែលមានប្រភពមកពីក្រៅប្រទេសកម្ពុជា និងមានគោលដៅវាយប្រហារលើពលករខ្មែរដែលកំពុងស្នាក់នៅឯបរទេស។

# ៧. អនុសាសន៍

## ៧.១ សម្រាប់អង្គការសង្គមស៊ីវិល

1. អង្គការសង្គមស៊ីវិលដែលធ្វើការលើផ្នែកសិទ្ធិការងារ និងសិទ្ធិមនុស្ស ត្រូវតែចាត់ទុកសកម្មភាពមិនពិតប្រាកដដែលសហការគ្នាជាប្រព័ន្ធ (Coordinated Inauthentic Behavior) នៅលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) ថាជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរ និងកំពុងបន្តកើតមាន។ អង្គការទាំងអស់មិនគួរមើលរំលង ឬធ្វើប្រហែសចំពោះទម្រង់លំនាំមិនប្រក្រតីដែលលេចឡើងនៅក្នុងផ្នែកបញ្ចេញមតិរបស់ទំព័រហ្វេសប៊ុករបស់ខ្លួនឡើយ។ រាល់អត្ថបទបង្ហោះណាដែលមានមតិយោបល់គួរឱ្យសង្ស័យ គួរតែត្រូវបានកត់ត្រាទុកជាឯកសារ ពីព្រោះភស្តុតាងទាំងនេះនឹងប្រមូលផ្តុំទៅតាមពេលវេលា ដែលមានលំនាំច្បាស់លាស់មួយដែលមិនអាចប្រកែកបាននៅពេលក្រោយ។

2. អង្គការសង្គមស៊ីវិលគួរតែរួមគ្នាជាក្រុម ដើម្បីបង្កើតប្រព័ន្ធតាមដានរួមគ្នាមួយ ក្នុងការប្រមូល តាមដាន និងរក្សាទុកនូវភស្តុតាងនៃសកម្មភាពមិនពិតប្រាកដទាំងនោះ ដែលធ្វើការបង្ហោះឆ្លងកាត់ទំព័រហ្វេសប៊ុករបស់អង្គការទាំងអស់។ មូលដ្ឋានទិន្នន័យភស្តុតាងរួមដែលគ្របដណ្តប់លើអង្គការជាច្រើន គឺមានទម្ងន់រឹងមាំជាងការកត់ត្រាដោយដាច់ឡែកពីគ្នារបស់អង្គការសាមីនីមួយៗ ហើយវានឹងជួយគាំទ្រដល់ចំណាត់ការនានាទៅថ្ងៃអនាគត។

3. អង្គការសង្គមស៊ីវិលគួរតែភ្ជាប់ទំនាក់ទំនងដែលមានស្រាប់របស់ខ្លួនជាមួយក្រុមហ៊ុនមេតា (Meta) ដើម្បីជូនដំណឹងជាផ្លូវការទៅកាន់ក្រុមហ៊ុន Meta អំពីបណ្តាញគណនីមិនពិតប្រាកដនេះ។ អង្គការណាដែលមានទំនាក់ទំនងជាមួយក្រុមហ៊ុន Meta រួចជាស្រេច តាមរយៈបណ្តាញសិទ្ធិឌីជីថល ភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬកម្មវិធី Platform Trust Programs គួរតែប្រើប្រាស់ប

ណ្ដាញទាំងនោះដើម្បីរាយការណ៍ និងជម្រុញបញ្ហានេះទៅកាន់ថ្នាក់លើដោយផ្ទាល់ ព្រមទាំងចែករំលែកភស្តុតាងដែលបានកត់ត្រាទុកនៅក្នុងរបាយការណ៍នេះ ទៅជាផ្នែកមួយនៃការជូនដំណឹងនោះ។

*------ បញ្ចប់នៃរបាយការណ៍ ------*

## ប្រភពទិន្នន័យយោង

របាយការណ៍នេះត្រូវបានចែករំលែកទៅកាន់បណ្ដាអង្គការទាំងអស់ដែលស្ថិតក្រោមការតាមដាន។ ទោះជាយ៉ាងណាក៏ដោយ ឯកសារទិន្នន័យ Excel ត្រូវបានរៀបចំឡើងសម្រាប់តែអង្គការចំនួនប្រាំមួយ ដែលមតិយោបល់របស់ពួកគេត្រូវបានជ្រើសរើសសម្រាប់ការវិភាគលម្អិតប៉ុណ្ណោះ រួមមាន៖ អាដហុក (Adhoc), មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR), សង់ត្រាល់ (CENTRAL), កំហ្វ្រែល (Comfrel), លីកាដូ (Licadho) និងប្រជាកសិករ (ProcheaKaset)។ ឯកសារនីមួយៗត្រូវបានផ្ដល់ជូនទៅឱ្យតែអង្គការសាមីដែលជាម្ចាស់ទិន្នន័យប៉ុណ្ណោះ ដោយសារវាមានផ្ទុកនូវទិន្នន័យមតិយោបល់លម្អិតដែលប្រមូលបានពីទំព័រហ្វេសប៊ុក (Facebook) របស់ពួកគេ។ ឯកសារទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ។

អង្គការដែលបានទទួលឯកសារទិន្នន័យរបស់ខ្លួន អាចប្រើប្រាស់វាសម្រាប់ការពិនិត្យឡើងវិញផ្ទៃក្នុង និងសម្រាប់រៀបចំផែនការឆ្លើយតបផ្ទាល់ខ្លួន។ សាធារណជន ឬអង្គការផ្សេងទៀតដែលចង់ទទួលបានទិន្នន័យទាំងនេះ គួរតែទាក់ទងទៅកាន់អង្គការសាមីពាក់ព័ន្ធដោយផ្ទាល់។ លទ្ធផលនៃការស្រាវជ្រាវនៅក្នុងរបាយការណ៍នេះ គឺផ្អែកលើទិន្នន័យដែលបានប្រមូល និងរក្សាទុកនៅក្នុងឯកសារ Excel ដូចខាងក្រោម។ ឯកសារនីមួយៗមានផ្ទុកនូវទិន្នន័យមតិយោបល់ ទិន្នន័យគណនី និងសន្លឹកកិច្ចការវិភាគ (Analysis sheets) សម្រាប់អង្គការនីមួយៗដែលមានរាយនាម៖

Adhoc. (Adhoc_Comment_Analysis_Feb_Apr_2026.xlsx). Contains comment analysis for 3 posts (587 comments). Includes Summary, per-post sheets, Flagged Only, Manipulation Patterns, and Account Analysis sheets.

CCHR. (CCHR_Comment_Analysis_Feb_Apr_2026.xlsx). Contains comment analysis for 1 post (35 comments). Includes Summary, per-post sheet, Flagged Only, Manipulation Patterns, and Account Analysis sheets.

CENTRAL. (CENTRAL_Post_[Post ID]_Comment_Analysis_Feb_Apr_2026.xlsx (41 files)). One file per post. Each file contains comment analysis, account data, and Account Analysis sheet for each of the 41 CENTRAL posts analyzed (1,811 comments total).

Comfrel. (Comfrel_Comment_Analysis_Feb_Apr_2026.xlsx). Contains comment analysis for 4 posts (372 comments). Includes Summary, per-post sheets, Flagged Only, Manipulation Patterns, and Account Analysis sheets.

Licadho. (Licadho_Comment_Analysis_Feb_Apr_2026.xlsx). Contains comment analysis for 4 posts (2,385 comments). Includes Summary, per-post sheets, Flagged Only, Manipulation Patterns, and Account Analysis sheets.

ProcheaKaset. (ProcheaKaset_Comment_Analysis_Feb_Apr_2026.xlsx). Contains comment analysis for 1 post (891 comments). Includes Summary, per-post sheet, Flagged Only, Manipulation Patterns, and Account Analysis sheets.